ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

***

ឆ្នាំទី ៤ លេខ ២៤ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៦

រាជកិច្ច

រួមមាន៖

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

ក

មាតិកា

I . ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រម

១៧-៦-១៩៩៦- ព្រះរាជក្រម ជស/រកម/០៦៩៦/០៣ ច្បាប់ស្តីពីលក្ខន្តិកៈ
ទូទៅ នៃសហគ្រាសសាធារណៈ ១០២៩

II - ទីស្តីការគណៈរដ្ឋមន្ត្រី

១-អនុក្រឹត្យ

២៥-៦-១៩៩៦ – អនុក្រឹត្យលេខ ៣២ អនក្រ.បក ស្តីពីការចាត់តាំង និងការ
ប្រព្រឹត្តិទៅ នៃប្រព័ន្ធសំរបសំរួលផ្ទៃក្នុង (Internal Coordination
Network) ១០៤៣

២៥-៦-១៩៩៦ – អនុក្រឹត្យលេខ ១១៧ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១០៤៩

២៧-៦-១៩៩៦ – អនុក្រឹត្យលេខ ១១៨ អនក្រ.តត ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ ១០៥០

២៧-៦-១៩៩៦ – អនុក្រឹត្យលេខ ១១៩ អនក្រ.តត ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ ១០៥១

២៧-៦-១៩៩៦ – អនុក្រឹត្យលេខ ១២០ អនក្រ.តត ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ ១០៥២

២៧-៦-១៩៩៦ – អនុក្រឹត្យលេខ ១២១ អនក្រ.តត ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ ១០៥៣

២៨-៦-១៩៩៦ – អនុក្រឹត្យលេខ ១២២ អនក្រ.តត ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ ១០៥៤

២-សេចក្តីសំរេច

២៥-៦-១៩៩៦ – សេចក្តីសំរេចលេខ ២៤ សសរ ស្តីពីការបង្កើតគណៈកម្មការ
ដឹកជញ្ជូនទំនិញពិសេស ១០៥៥

III - ការងារបណ្តាក្រសួង

១-ទីស្តីការរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាស

២៦-៦-១៩៩៦ - ប្រកាសលេខ ២០០ ប្រក.សហវ ស្តីពីការប្រើប្រាស់ជំនួយទ្រទ្រង់ថវិកា និង មូលនិធិបដិភាគក្នុងកិច្ច ប្រតិបត្តិការពិសេស ១០៥៧

២-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

២៤-៦-១៩៩៦ - ប្រកាសលេខ ៤០៦ ផក.ប្រក អនុញ្ញាតអោយលោក ឈួន លឹម ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១២០ សេះ ១០៦០

២៤-៦-១៩៩៦ - ប្រកាសលេខ ៤០៧ ផក.ប្រក អនុញ្ញាតអោយលោក ទឹម យ៉ុន ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៤០ សេះ ១០៦០

២៤-៦-១៩៩៦ - ប្រកាសលេខ ៤០៨ ផក.ប្រក អនុញ្ញាតអោយក្រុមហ៊ុន ខ្វលីធី តេក្សស្ទីល ខូអែលធីឌី (**Quality Textiles Co.LTD**) តំណាងដោយលោក SEOW FUI CHEONG សញ្ជាតិម៉ាឡេស៊ី បង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញ ១០៦១

២៤-៦-១៩៩៦ - ប្រកាសលេខ ៤០៩ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី អេសខ្វាន ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការសិប្បកម្ម ផលិតទឹកស៊ីអ៊ីវសញ្ញា «រូបភ្នំពីរ» ១០៦២

២៤-៦-១៩៩៦ – ប្រកាសលេខ ៤១០ ផក.ប្រក អនុញ្ញាតអោយលោក ឃៀន ខាន់ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការ រោងម៉ាស៊ីនកិនស្រូវកំលាំង ៦០ សេះ ១០៦២
២៤-៦-១៩៩៦ – ប្រកាសលេខ ៤១១ ផក.ប្រក អនុញ្ញាតអោយលោក ចៅ ទ្រី ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនកិន ស្រូវកំលាំង ៦០ សេះ ១០៦៣

៣-ទីស្តីការក្រសួងព័ត៌មាន

ប្រកាស

២៤-៦-១៩៩៦ – ប្រកាសលេខ ១៨៤/៩៦ ពម.បណ.ប្រក ស្តីពីការតែងតាំង មន្ត្រីរាជការ ១០៦៤
២៤-៦-១៩៩៦ – ប្រកាសលេខ ១៨៦/៩៦ ពម.មព.ប្រក អនុញ្ញាតអោយកាសែត ឈ្មោះ «សម្លេងសច្ចៈ» បោះពុម្ពចែកផ្សាយ ១០៦៥
២៤-៦-១៩៩៦ – ប្រកាសលេខ ១៨៧/៩៦ ពម.មព.ប្រក អនុញ្ញាតអោយកាសែត សម្លេងរាស្ត្រខ្មែរ បោះពុម្ពចែកផ្សាយ ១០៦៦
២៤-៦-១៩៩៦ – ប្រកាសលេខ ១៩០/៩៦ ពម.មពប្រក ស្តីពីការតែងតាំងមន្ត្រី រាជការ ១០៦៨
២៤-៦-១៩៩៦ – ប្រកាសលេខ ១៩១/៩៦ ពម.មព.ប្រក អនុញ្ញាតអោយលោក កូហ្សីតេហ៊ិរូតា ប្រធានអង្គការជំនួយជប៉ុន បោះពុម្ពចែកផ្សាយ នូវសៀវភៅ និងផ្ទាំងរូបភាព ១០៦៩
២៤-៦-១៩៩៦ – ប្រកាសលេខ ១៩២/៩៦ ពម.មព.ប្រក អនុញ្ញាតអោយកាសែត «ភ្នំពេញ» បោះពុម្ពចែកផ្សាយ ១០៧១
២៦-៦-១៩៩៦ – ប្រកាសលេខ ១៩៣/៩៦ ពម.បណ.ប្រក ស្តីពីការតែងតាំង មន្ត្រីរាជការ ១០៧២

២៨-៦-១៩៩៦ – ប្រកាសលេខ ១៩៤/៩៦ ពម.បសទ.ប្រក អនុញ្ញាតអោយ
លោក IVAN J. BROOKFIELD សញ្ជាតិអូស្ត្រាលី បើក
ស្ថានីយវិទ្យុផ្សាយសំលេង FM 101 Mhz ១០៧៣

៤-ទីស្ដីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ប្រកាស

២៧-៦-១៩៩៦- ប្រកាសលេខ ៣៥៩ ប្រក.កសក.ចត ស្ដីពីការបង្កើត
ការិយាល័យ អាស៊ាន កសិកម្ម ១០៧៥
២៧-៦-១៩៩៦- ប្រកាសលេខ ៣៦០ ប្រក.កសក.ចត ស្ដីពីការរំសាយអង្គភាព ១០៧៦

៥_ទីស្ដីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

ប្រកាស

២៨_៦_១៩៩៦ – ប្រកាសលេខ ៦២២ អយក.ប្រក ស្ដីពីការប្ដូរឈ្មោះសាលាបឋមសិក្សា
«ហ៊ុន សែន អ្នកលឿង» ១០៧៨

៦ - ស្ដីពីការក្រសួងធម្មការ និង សាសនា

ប្រកាស

២៦-៦-១៩៩៦- ប្រកាសលេខ ១២០/៩៦ កធស ស្ដីពីការតែងតាំងគណៈកម្មការ
អភិវឌ្ឍន៍ពុទ្ធិកសិក្សា ១០៧៩

I - ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រម

ព្រះរាជក្រម ជស/រកម/០៦៩៦/០៣

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុងកម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស-រកត-១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត-១០៩៤-៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស-រកម-០១៩៦-១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និង អំពីទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាសអោយប្រើ

ច្បាប់ស្តីពីលក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២២ ឆ្នាំ ១៩៩៦ នាសម័យប្រជុំលើកទី ៦ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

ច្បាប់

ស្តីពី

លក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

ជំពូកទី ១

បទបញ្ញត្តិទូទៅ

មាត្រា ១ .-

ច្បាប់នេះមានគោលដៅគ្រប់គ្រងផ្នែកសហគ្រាសសាធារណៈនិងកំណត់លក្ខខណ្ឌដែលត្រូវអនុវត្តចំពោះលក្ខន្តិកៈគតិយុត្តិ ការប្រព្រឹត្តិទៅ និង ការត្រួតពិនិត្យ ។

សហគ្រាសសាធារណៈ គឺជាសហគ្រាសដែលមានដើមទុនទាំងអស់ ឬ ភាគច្រើនជារបស់រដ្ឋ ។

មាត្រា ២ .-

សហគ្រាសសាធារណៈ គឺជាសហគ្រាសដែលមានដើមទុនទាំងអស់ ឬ ភាគច្រើនជារបស់រដ្ឋ ។ សហគ្រាសសាធារណៈមានបេសកម្មបង្គួលក្ខណៈដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និង សង្គមកិច្ចជាអាទិ៍ក្នុងការបង្កើតតម្លៃធនធានធម្មជាតិ និងការបង្កើតអាជីព ។

មាត្រា ៣ .-

សហគ្រាសសាធារណៈមានទម្រង់ជា :

– គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច

– ក្រុមហ៊ុនរដ្ឋ

-ក្រុមហ៊ុនចំរុះដែលក្នុងនោះរដ្ឋកាន់កាប់ដោយផ្ទាល់ ឬ ដោយប្រយោលលើស ពី ៥១ ភាគរយ នៃដើមទុនក្រុមហ៊ុន ឬសិទ្ធិបោះឆ្នោត ។

មាត្រា ៤ .-

សហគ្រាសសាធារណៈ គឺជានីតិបុគ្គលដែលមានស្វ័យភាពហិរញ្ញវត្ថុ ។

ក្រុមប្រឹក្សាភិបាលសហគ្រាសសាធារណៈដែលតទៅនេះហៅកាត់ថា ក្រុមប្រឹក្សាភិបាល ជាអង្គការដឹកនាំខ្ពស់បំផុតនៅក្នុងសហគ្រាសសាធារណៈ ហើយបំពេញមុខងារប្រកបដោយស្វ័យភាព ពេញលេញ ចំនួនសមាជិកនៃក្រុមប្រឹក្សាភិបាលមិនត្រូវលើសពីប្រាំពីរ រូបឡើយ ។

វៀរលែងតែមានចែងក្នុងបទបញ្ញត្តិទាំងឡាយនៃច្បាប់នេះ ការគ្រប់គ្រងលើគ្រប់ផ្នែករបស់សហគ្រាសសាធារណៈត្រូវអនុលោមតាមគោលការណ៍ និង បែបបទទាំងឡាយនៃនីតិក្រុមហ៊ុនពាណិជ្ជកម្ម ។

មាត្រា ៥ .-

លើកលែងតែមានបដិបញ្ញត្តិដែលចែងដោយច្បាប់ សហគ្រាសសាធារណៈ ត្រូវស្ថិតនៅក្រោមរបបនីតិរូមចំពោះពន្ធនិងអាករ ។

មាត្រា ៦ .-

សហគ្រាសសាធារណៈ ត្រូវស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេស នៃ ក្រសួងអាជ្ញាធរសាធារណៈណាមួយអាស្រ័យលើប្រភេទនៃសកម្មភាព របស់សហគ្រាសនោះ ។

មាត្រា ៧ .-

សហគ្រាសសាធារណៈ ត្រូវស្ថិតនៅក្រោម ÷

- ការត្រួតពិនិត្យរបស់រដ្ឋដូចមានចែងនៅក្នុងផ្នែកទី ៣ ជំពូកទី ២ នៃ ច្បាប់នេះ
- ការត្រួតពិនិត្យហិរញ្ញវត្ថុ និងអធិការកិច្ចរបស់ក្រសួង ឬស្ថាប័នពាក់ព័ន្ធ

មាត្រា ៨ .-

បុគ្គលិកដែលធ្វើការក្នុងសហគ្រាសសាធារណៈ ត្រូវស្ថិតនៅក្រោមលក្ខន្តិកៈដោយឡែកដែលសម្រេចដោយក្រុមប្រឹក្សាភិបាល ។

ជំពូកទី ២

បទបញ្ញត្តិរួមសម្រាប់សហគ្រាសសាធារណៈ

ផ្នែកទី ១

ភារកិច្ចនិងការប្រព្រឹត្តិទៅរបស់ក្រុមប្រឹក្សាភិបាល

មាត្រា ៩ .-

ក្នុងចំណោមសមាជិកក្រុមប្រឹក្សាភិបាល ត្រូវមានអាសនៈមួយកន្លែងសម្រាប់តំណាងនិយោជិត នៃសហគ្រាសសាធារណៈ ដែលត្រូវបានបោះឆ្នោតជ្រើសរើសតាំងចេញពីនិយោជិត និងដោយនិយោជិតរបស់សហគ្រាស ។

មាត្រា ១០ .-

ក្រុមប្រឹក្សាភិបាលផ្ទេរអោយប្រធានអគ្គនាយក ឬ អគ្គនាយកនូវអំណាចចាំបាច់សម្រាប់ដំណើរការសហគ្រាសប្រចាំថ្ងៃ តែការផ្ទេរអំណាចនេះមិនមែនជាការផ្ទេរការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលឡើយ ។

មុខងារនៃប្រធានអគ្គនាយក អគ្គនាយក ឬសមាជិកក្រុមប្រឹក្សាភិបាល នៃ សហគ្រាសសាធារណៈមានវិសមិតភាពជាមួយមុខងារ នៃ សមាជិករដ្ឋសភាឬសមាជិក រាជរដ្ឋាភិបាល ។

មាត្រា ១១ .-

ក្រុមប្រឹក្សាភិបាលកំណត់ទិសដៅ និងត្រួតពិនិត្យការគ្រប់គ្រងសហគ្រាសព្រមទាំងធានាសនិទានភាព និងប្រសិទ្ធភាពនៃការរៀបចំ និង ការប្រព្រឹត្តិទៅរបស់សហគ្រាស ។

ដើម្បីបំពេញមុខងារនេះក្រុមប្រឹក្សាភិបាលមានភារកិច្ចជាអាទិ៍ដូចតទៅ :

- សម្រេចគម្រោងអភិវឌ្ឍន៍សហគ្រាស
- វាយតម្លៃក្នុងចន្លោះពេលមួយទៀងទាត់នូវលទ្ធផលសម្រេចបាន និងលើកវិធានការកែតម្រូវសំរាប់អនុវត្ត
- សម្រេចគម្រោងថវិកាសំរាប់ការប្រព្រឹត្តទៅនិងការវិនិយោគ ព្រមទាំងសេវាហិរញ្ញប្បទាន
- អនុម័តតុល្យការ និងគណនីគ្រប់គ្រង

- កំណត់រចនាសម្ព័ន្ធរបស់សហគ្រាស លក្ខន្តិកៈបុគ្គលិក និងរបបបៀវត្ស
- អនុម័តការដេញថ្លៃសាធារណៈ

មាត្រា ១២ .-

ក្រុមប្រឹក្សាភិបាល ត្រូវប្រជុំយ៉ាងតិចមួយដងក្នុងរៀងរាល់ ៣ ខែ ដើម្បី ពិភាក្សា និង សម្រេចនូវបញ្ហាដែលមានចុះក្នុងរបៀបវារៈ ។ របៀបវារៈនេះនឹងត្រូវ បានជូនដំណឹងជាមុនយ៉ាងតិច ១០ ថ្ងៃ ដល់គ្រប់សមាជិកក្រុមប្រឹក្សាភិបាល មន្ត្រីត្រួតពិនិត្យរដ្ឋ និងក្រសួងអាណាព្យាបាល ឬ អាជ្ញាធរអាណាព្យាបាល ។

ក្រុមប្រឹក្សាភិបាល ត្រូវចាត់ចែងធ្វើកំណត់ហេតុនានាអោយហើយក្នុងរយៈពេល ១០ ថ្ងៃ បន្ទាប់ពីការប្រជុំ ។

មាត្រា ១៣ .-

វៀរលែងតែមានចែងក្នុងបទបញ្ញត្តិនៃលក្ខន្តិកៈ ឬបទបញ្ញាដែលទាក់ទងទៅ នឹងការរៀបចំ និងការប្រព្រឹត្តទៅរបស់សហគ្រាសសាធារណៈណាមួយ ក្រុមប្រឹក្សាភិបាល អាចប្រជុំដាយចាត់ទុកជាបានការលុះត្រាតែមានសមាជិកភាគច្រើនចូលរួម ។ ក្រុមប្រឹក្សាភិបាលត្រូវសម្រេចតាមសំលេងភាគច្រើននៃសមាជិកវត្តមាន ។ ក្នុងករណីដែលមានសម្លេងស្មើគ្នានោះ សម្លេងរបស់ប្រធានក្រុមប្រឹក្សាភិបាលមានឧត្តមានុភាព ។

មាត្រា ១៤ .-

ក្រុមប្រឹក្សាភិបាលត្រូវសម្រេចយ៉ាងយូរបំផុតនៅថ្ងៃទី ៣០ ខែកញ្ញា រៀងរាល់ឆ្នាំ នូវគម្រោងថវិកាសំរាប់ការប្រព្រឹត្តិទៅនឹងការវិនិយោគ ព្រមទាំងសេមាហិរញ្ញប្បទាន ។

ឯកសារទាំងនេះ ត្រូវបានទទួលការយល់ព្រមពីក្រសួងអាណាព្យាបាល ឬ អាជ្ញាធរអាណាព្យាបាលបន្ទាប់ពីការផ្តល់យោបល់ឯកភាពពរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុក្នុងរយៈពេលអតិបរមា ២ ខែ គិតចាប់ពីថ្ងៃដែលឯកសារ មកដល់ក្រសួងអាណាព្យាបាល ឬ អាជ្ញាធរអាណាព្យាបាល ។

មាត្រា ១៥ .-

ក្រុមប្រឹក្សាភិបាល ត្រូវសំរេចលើរបាយការណ៍ស្តីពីសកម្មភាពប្រចាំឆ្នាំ តុល្យការ និងគណនីគ្រប់គ្រងព្រមទាំងឯកសារឧបសម្ព័ន្ធនានាយ៉ាងយូរបំផុត ៣ ខែ ក្រោយពេលបិទបញ្ជី ។

ផ្នែកទី ២

ភាតព្វកិច្ចរបស់សហគ្រាសសាធារណៈ

មាត្រា ១៦ .-

សហគ្រាសសាធារណៈត្រូវផ្តល់ជូនទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាលនូវឯកសារដូច តទៅដែលពាក់ព័ន្ធទៅនឹង ÷

- កំណត់ហេតុប្រជុំក្រុមប្រឹក្សាភិបាល
- ថវិកា សម្រាប់ការប្រព្រឹត្តិទៅនិងការវិនិយោគ
- របាយការណ៍ស្តីពីសកម្មភាព តុល្យការ និងគណនីគ្រប់គ្រងព្រមទាំងឯកសារឧបសម្ព័ន្ធ
- របាយការណ៍ស្តីពីការត្រួតពិនិត្យគណនីនានា ។

ឯកសារនីមួយៗ ដែលធ្វើហើយស្រេចតាមកាលកំណត់ ត្រូវបានបញ្ជូនទៅអោយកន្លែងទទួលក្នុងរយៈពេលមិនលើសពី ១៥ ថ្ងៃ ។

ក្រសួងអាណាព្យាបាល ឬ អាជ្ញាធរអាណាព្យាបាលមានរយៈពេល ១ ខែ សម្រាប់ជំទាស់ក្នុងករណីចាំបាច់ ។ ក្រុមប្រឹក្សាភិបាលត្រូវបានផ្តល់ពត៌មាន អំពីខ្លឹមសារនៃការជំទាស់នៅពេលប្រជុំបន្ទាប់ដើម្បីចាត់វិធានការ ។

ក្នុងករណីដែលក្រុមប្រឹក្សាភិបាលមិនទទួលការជំទាស់របស់ក្រសួងអាណាព្យាបាលឬអាជ្ញាធរអាណាព្យាបាលនោះ ក្រុមប្រឹក្សាភិបាលត្រូវបង្ហាញហេតុផលហើយ ត្រូវជូនដំណឹងទៅក្រសួងអាណាព្យាបាលឬអាជ្ញាធរអាណាព្យាបាលវិញជាបន្ទាន់ ។

មាត្រា ១៧ .-

គណនីទាំងឡាយរបស់សហគ្រាសសាធារណៈ ត្រូវបានដាក់អោយស្ថិតនៅក្រោមការត្រួតពិនិត្យពីអ្នកជំនាញគណនេយ្យតាមលក្ខណ្ឌនិងបែបបទ ដែលកំណត់ដោអនុក្រឹត្យ ។

មាត្រា ១៨ .-

លទ្ធកម្មដោយសហគ្រាសសាធារណៈ ដាច់ខាតត្រូវធ្វើឡើងដោយអនុលោមតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

មាត្រា ១៩ .-

វិធានការជិញថ្លៃការអនុវត្តនិងការត្រួតពិនិត្យការដេញថ្លៃត្រូវបានកំណត់ដោយអនុក្រឹត្យ ។

ផ្នែកទី៣

ការត្រួតពិនិត្យសហគ្រាសសាធារណៈ

មាត្រា ២០ .-

ក្រសួងអាណាព្យាបាលឬអាជ្ញាធរអាណាព្យាបាល ត្រូវធ្វើការត្រួតពិនិត្យសេដ្ឋកិច្ច ដល់សហគ្រាសតាមរយៈតំណាងរបស់ខ្លួនដែលនៅក្នុងក្រុមប្រឹក្សាភិបាល ។ ការត្រួតពិនិត្យសេដ្ឋកិច្ចត្រូវបានធ្វើឡើងដើម្បីធានាអោយសេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាល មានលក្ខណៈអនុលោមតាមទិសដៅរបស់រាជរដ្ឋាភិបាល ឬ តាមការណែនាំរបស់ក្រសួងអាណាព្យាបាលឬអាជ្ញាធរអាណាព្យាបាល ។

មាត្រា ២១ .-

ត្រូវបានដាក់អោយនៅអមសហគ្រាសសាធារណៈនីមួយៗ នូវមន្ត្រីត្រួតពិនិត្យរដ្ឋដែលទទួលបន្ទុកខាងការងារត្រួតពិនិត្យជាអាទិ៍លើ ÷

–ការបំពេញកាតព្វកិច្ចរបស់សហគ្រាសសាធារណៈ ដែលមានចែងក្នុងច្បាប់និងបទបញ្ញាទាំងឡាយជាធរមាន

–ការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល

–ការតាមដានការប្រព្រឹត្យទៅ និងការវិវឌ្ឍន៍របស់សហគ្រាស

-ប្រក្រតីភាពនៃសកម្មភាពទាំងឡាយ ដែលអាចជះឥទ្ធិពលដល់ស្ថានភាព ហិរញ្ញវត្ថុរបស់សហគ្រាស ។

មាត្រា ២២ .-

មន្ត្រីត្រួតពិនិត្យរដ្ឋ ត្រូវបានតែងតាំងនិងបញ្ឈប់ពីតំណែងដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

មន្ត្រីត្រួតពិនិត្យរដ្ឋត្រូវបានជ្រើសរើសពីក្នុងចំណោមមន្ត្រីជាន់ខ្ពស់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលបាននិងកំពុងបំពេញការងារសាធារណៈយ៉ាងតិច ៥ ឆ្នាំ ។

មន្ត្រីត្រួតពិនិត្យរដ្ឋត្រូវបំពេញភារកិច្ចតាមការណែនាំរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ហើយត្រូវរាយការណ៍ជូនក្រសួងអោយបានទៀងទាត់ អំពីការបំពេញ ភារកិច្ចរបស់ខ្លួន ។

មាត្រា ២៣ .-

មន្ត្រីត្រួតពិនិត្យរដ្ឋត្រូវចូលរួមក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល មានសិទ្ធិផ្តល់យោបល់ពិគ្រោះ និងត្រូវបានអញ្ជើញអោយចូលរួមក្នុងមហាសន្និបាតជាទៀងទាត់ ។

មន្ត្រីត្រួតពិនិត្យរដ្ឋ ត្រូវផ្តល់យោបល់លើបញ្ហាដែលមានចុះក្នុងរបៀបវារៈ នៃអង្គប្រជុំក្រុមប្រឹក្សាភិបាលក្នុងការអនុវត្តភារកិច្ចនេះ មន្ត្រីត្រួតពិនិត្យរដ្ឋអាចស្នើសុំពត៌មាន ឬ ស្វែងយល់នៅនឹងកន្លែងអំពីឯកសារ ឬបញ្ជីទាំងអស់ដែលមាននៅក្នុងសហគ្រាស ។

មាត្រា ២៤ .-

មន្ត្រីត្រួតពិនិត្យរដ្ឋអាចជំទាស់នឹងការចាត់វិធានការទាំងឡាយដែលខ្លួន យល់ឃើញថាផ្ទុយនឹងច្បាប់ និង ការប្រតិបត្តិដែលប៉ះពាល់ដល់សិទ្ធិនិងផល ប្រយោជន៍របស់សហគ្រាស ឬរបស់រដ្ឋពុំសមស្របនឹងគោលដៅរបស់សហគ្រាស ។

មាត្រា ២៥ .-

ការជំទាស់របស់មន្ត្រីត្រួតពិនិត្យរដ្ឋ ត្រូវបានជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាភិបាលនៅពេលប្រជុំឬយ៉ាងយូរបំផុតក្នុងរយៈពេល ៣ ថ្ងៃ « គិតតែថ្ងៃធ្វើការ» ក្រោយពីការប្រជុំរបស់ក្រុមប្រឹក្សាភិបាល ។

មន្ត្រីត្រួតពិនិត្យរដ្ឋ ត្រូវរាយការណ៍ជាបន្ទាន់ជូនក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឬ ក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាលបច្ចេកទេស នៃ សហគ្រាស អំពីការជំទាស់របស់ខ្លួនលើការអនុវត្តសេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល ។ ៤ ថ្ងៃធ្វើការ ក្រោយការជំទាស់របស់មន្ត្រីត្រួត

ពិនិត្យរដ្ឋ បើសិនជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬក្រសួងអាណាព្យាបាល ឬអាជ្ញាធរ អាណាព្យាបាលមិនបានបញ្ជាក់អំពីការជំទាស់នេះ ដោយចេញបញ្ជាអោយលុបចោល ឬ កែប្រែសេចក្តីសំរេចទេនោះ សេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល ត្រូវចាត់ទុកជាបានការ ។

ជំពូកទី ៣

បទបញ្ញត្តិដោយឡែក សំរាប់ប្រភេទផ្សេងៗនៃសហគ្រាសសាធារណៈ

ផ្នែកទី ១

គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច

មាត្រា ២៦ .-

គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ចគឺជានីតិបុគ្គល នៃ នីតិសាធារណៈដែលមាន ស្វ័យភាពហិរញ្ញវត្ថុ ។ គ្រឹះស្ថាននេះផលិតផលិតផល ឬ ធ្វើសេវា សំរាប់ទីផ្សារ ។

មាត្រា ២៧ .-

គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ចត្រូវបានបង្កើតឡើងដោយអនុក្រឹត្យតាមការស្នើរមក្នារបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងអាណាព្យាបាលឬអាជ្ញាធរ អាណាព្យាបាល ។ អនុក្រឹត្យនេះកំណត់ជាអាទិ៍អំពីភារកិច្ច ដើមទុន ក្រសួងអាណាព្យាបាល ឬ អាជ្ញាធរអាណាព្យាបាលសមាសភាពក្រុមប្រឹក្សាភិបាល ការរៀបចំរដ្ឋបាល និង ហិរញ្ញវត្ថុ វិធាននៃការប្រព្រឹត្តិទៅរបស់គ្រឹះស្ថាន ។

មាត្រា ២៨ .~.

គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច ត្រូវបានដឹកនាំដោយ ប្រធានអគ្គនាយក មួយរូបជាប្រធានក្រុមប្រឹក្សាភិបាលផងនិងជាអគ្គនាយកផង ដែលបំពេញមុខងារក្រោមការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាភិបាល ។

តួនាទីរបស់ប្រធានក្រុមប្រឹក្សាភិបាលនិងអគ្គនាយកអាចញែកចេញដាច់ពីគ្នា។ក្នុងករណីនេះ ទីចាត់ការប្រតិបត្តិនៃគ្រឹះស្ថានត្រូវបានដឹកនាំដោយអគ្គនាយក ។

មាត្រា ២៩ .~

ប្រធានអគ្គនាយក ឬ អគ្គនាយក ត្រូវបានតែងតាំងដោយអនុក្រឹត្យតាម សំណើរបស់ក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាលនៃគ្រឹះស្ថាន សាធារណៈនោះ ។ សមាជិកដទៃទៀតនៃក្រុមប្រឹក្សាភិបាល ត្រូវបានតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់ក្រសួង ឬ អាជ្ញាធរដែលជាសមាជិកនោះ ជាតំណាង និងត្រូវបានជ្រើសរើសតាមល័ក្ខខ័ណ្ឌដែលបានកំណត់ក្នុងមាត្រា ៤៣ នៃច្បាប់នេះ ។

ផ្នែកទី ២

ក្រុមហ៊ុនរដ្ឋ

មាត្រា ៣០ .~

ក្រុមហ៊ុនរដ្ឋ គឺជាក្រុមហ៊ុនដែលមានដើមទុនទាំងអស់ជារបស់រដ្ឋ ។

មាត្រា ៣១ .~

ក្រុមហ៊ុនរដ្ឋ ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យ តាមការស្នើរួមគ្នារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងក្រសួងអាណាព្យាបាល ឬ អាជ្ញាធរ អាណាព្យាបាល ។ អនុក្រឹត្យនេះកំណត់ជាអាទិ៍អំពីកម្មវត្ថុរបស់ក្រុមហ៊ុនទម្រង់ គតិយុត្តិ ក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាល របបត្រួតពិនិត្យដែលត្រូវអនុវត្ត សមាសភាពរបស់ក្រុមប្រឹក្សាភិបាល ។

មាត្រា ៣២ .-

ក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាលបច្ចេកទេសទទួលខុស ត្រូវបំពេញទម្រង់បែបបទនៃការបង្កើតក្រុមហ៊ុនដោយៈ

- រៀបចំលក្ខន្តិកៈរបស់ក្រុមហ៊ុនដោយមានការព្រមព្រៀងជាមួយ និង ក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។
- ចាត់ចែងចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម
- បំពេញទម្រង់បែបបទទាំងអស់តាមគោលការណ៍ និងបែបបទទាំងឡាយ នៃនីតិក្រុមហ៊ុនពាណិជ្ជកម្ម ។

មាត្រា ៣៣ .-

វៀរលែងតែមានចែងក្នុងបទបញ្ញត្តិទាំងឡាយនៃច្បាប់នេះលក្ខន្តិកៈរបស់ក្រុមហ៊ុនរដ្ឋកំណត ជាអាទិ៍អំពីចំនួនទឹកប្រាក់និងប្រភេទនៃភាគទុនការរៀបចំរដ្ឋបាល និង ហិរញ្ញវត្ថុ វិធាននៃការប្រព្រឹត្តិទៅរបស់ក្រុមហ៊ុន ។

មាត្រា ៣៤ .-

តាមបដិបញ្ញត្តិលើគោលការណ៍ និងបែបបទទាំងឡាយនៃនីតិក្រុមហ៊ុនពាណិជ្ជកម្ម អំណាចនៃមហាសន្និបាតរបស់ក្រុមហ៊ុនរដ្ឋ ត្រូវបានប្រគល់អោយក្រុមប្រឹក្សាភិបាល ។

មាត្រា ៣៥ .-

ភាគទុនដំបូងព្រមទាំងការកែប្រែជាក្រោយ នៃដើមទុនរបស់ក្រុមហ៊ុនរដ្ឋត្រូវបានធ្វើអោយសំរេចដោយអនុលោមតាមបទបញ្ញត្តិដែលមានចែងក្នុងច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ និង ច្បាប់ហិរញ្ញវត្ថុជាធរមាន ។

មាត្រា ៣៦ .-

ប្រធានអគ្គនាយក ឬ អគ្គនាយកក្រុមហ៊ុនរដ្ឋ ត្រូវបានតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាល ។ សមាជិកដទៃទៀត នៃក្រុមប្រឹក្សាភិបាលត្រូវបានតែងតាំងដោយអនុក្រឹត្យតាម សំណើរបស់ក្រសួង ឬ អាជ្ញាធរដែលសមាជិកនោះជាតំណាងនិងត្រូវបាន ជ្រើសរើសក្នុងលក្ខខ័ណ្ឌដែលបានកំណត់ក្នុង មាត្រា ៤៣ នៃច្បាប់នេះ ។

ជំពូកទី ៣
ក្រុមហ៊ុនចំរុះ

មាត្រា ៣៧ .-

ភាគកម្មសាធារណៈ គឺជាចំណែកនៃដើមទុនរបស់ក្រុមហ៊ុនចំរុះ ដែលកាន់កាប់ដោយរដ្ឋ ដោយគ្រឹះស្ថានសាធារណៈ ឬដោយក្រុមហ៊ុនរដ្ឋ ។

មាត្រា ៣៨ .-

ក្រុមហ៊ុនចំរុះ គឺជាក្រុមហ៊ុនដែលត្រូវបានបង្កើតឡើងតាមគោលការណ៍ និងតាមបែបបទទាំងឡាយនៃនីតិក្រុមហ៊ុនពាណិជ្ជកម្ម ហើយដែលដើមទុនត្រូវបានកាន់កាប់រួមគ្នាដោយនីតិបុគ្គល ឬ រូបវន្តបុគ្គលឯកជន និងនីតិបុគ្គលរដ្ឋ ។

កាលណាភាគកម្មសាធារណៈលើសពី ៥១ ភាគរយនៃដើមទុន ឬ សិទ្ធិបោះឆ្នោតក្រុមហ៊ុនចំរុះត្រូវបានចាត់ទុកជាសហគ្រាសសាធារណៈ ។

មាត្រា ៣៩ .-

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរ៉ាប់រងខាងផ្នែករដ្ឋបាលលើភាគកម្មសាធារណៈ ។

មាត្រា ៤០ .-

ប្រតិបត្តិការហិរញ្ញវត្ថុអំពីភាគកម្មសាធារណៈ ត្រូវបានធ្វើអោយសំរេចដោយអនុលោមតាមបទបញ្ញត្តិដែលមានចែងក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ និង ច្បាប់ហិរញ្ញវត្ថុ ជាធរមាន ។

មាត្រា ៤១ .-

តាមបដិបញ្ញត្តិលើគោលការណ៍ និងបែបបទទាំងឡាយនៃនីតិក្រុមហ៊ុន ពាណិជ្ជកម្ម រដ្ឋគ្រឹះស្ថានសាធារណៈ និងក្រុមហ៊ុនរដ្ឋ ត្រូវបានលើកលែងការ តំកល់ភាគហ៊ុនធានា សំរាប់តំណាងនៅក្នុងក្រុមប្រឹក្សាភិបាលសហគ្រាសដែលខ្លួនបានចូលរួម ។

មាត្រា ៤២-

តំណាងរបស់រដ្ឋ ឬ តំណាងរបស់គ្រឹះស្ថានសាធារណៈ នៅក្នុងក្រុមប្រឹក្សាភិបាល នៃក្រុមហ៊ុនចំរុះ ត្រូវបានតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

តំណាងរបស់ក្រុមហ៊ុនរដ្ឋនៅក្នុងក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនចំរុះ ត្រូវបានតែងតាំងដោយសេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុននោះ ក្រោយពីមានយោបល់ឯកភាពរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

មាត្រា ៤៣ .-

តំណាងរបស់រដ្ឋ របស់គ្រឹះស្ថានសាធារណៈ ឬរបស់ក្រុមហ៊ុនរដ្ឋនៅក្នុងក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនចំរុះត្រូវបានជ្រើសរើសដោយផ្អែកលើគុណសម្បត្តិ និងបទពិសោធន៍របស់ខ្លួន ឬ មួយពីក្នុងចំណោមមន្ត្រីរាជការបំរើការងារយ៉ាង តិច ៥ ឆ្នាំ ឬចូលនិវត្តន៍តែ មានអាយុមិនលើសពី ៦៥ ឆ្នាំឬមួយពីក្នុងចំណោមឥស្សរជន ខ្មែរដែលមានសមត្ថភាពខាងសេដ្ឋកិច្ច ខាងនីតិសាស្ត្រ ឬ ខាងវិទ្យាសាស្ត្រ ។

តំណាងទាំងនោះ អាចអោយរួចផុតពីការបង់ប្រាក់ធានាសំរាប់មុខតំណែងនៅក្នុងក្រុមប្រឹក្សាភិបាលតែមិនត្រូវមានភាគហ៊ុនក្នុងសហគ្រាសឡើយ ។

មាត្រា ៤៤ .-

ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី របស់តំណាងទាំងនោះក្នុងការបំពេញភារកិច្ចរបស់ខ្លួននៅក្នុងក្រុមប្រឹក្សាភិបាល នៃក្រុមហ៊ុនចំរុះត្រូវធ្លាក់លើរដ្ឋ លើគ្រឹះ ស្ថានសាធារណៈ ឬលើក្រុមហ៊ុនរដ្ឋ តែតំណាងត្រូវទទួលខុសត្រូវដោយខ្លួនឯងខាង ផ្នែកព្រហ្មទណ្ឌ ។

មាត្រា ៤៥ .-

ហាមដាច់ខាតមិនអោយមន្ត្រីសាធារណៈដែលធ្លាប់ធ្វើជាតំណាងរបស់រដ្ឋ របស់គ្រឹះស្ថានសាធារណៈឬរបស់ក្រុមហ៊ុនរដ្ឋចូលធ្វើការនៅក្នុងមុខតំណែងណាមួយក្នុង សហគ្រាសដែលខ្លួនធ្លាប់ពាក់ព័ន្ធនៅមុនការផុតរយៈពេល ៣ ឆ្នាំ គិតចាប់ពីថ្ងៃឈប់ធ្វើការរបស់តំណាងនោះ លើកលែងតែមានការអនុញ្ញាតពិសេស ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

មាត្រា ៤៦ .-

ត្រូវមានអាណត្តិគាហកៈពិសេសមួយរូប តំណាងរដ្ឋនៅក្នុងមហាសន្និបាត ក្រុមហ៊ុនចំរុះ ។ អាណត្តិគាហកៈពិសេសមានវិសមិតភាពជាមួយតំណែងជាអគ្គនាយកនៃ សហគ្រាសនោះ ។

មាត្រា ៥៧ .-

អាណត្តិគាហកៈពិសេសមានភារកិច្ចការពារផលប្រយោជន៍រដ្ឋនៅក្នុងមហាសន្និបាតសាមញ្ញ និងវិសាមញ្ញ ហើយមានសិទ្ធិបោះឆ្នោតក្នុងនាមភាគីរដ្ឋ ។

មាត្រា ៥៨ .-

អាណត្តិគាហកៈពិសេស ត្រូវបានជ្រើសរើសពីក្នុងចំណោមមន្ត្រីរាជការដែលបាន និង កំពុងបំរើការងារយ៉ាងតិច ៥ ឆ្នាំ ។ អាណត្តិគាហកៈពិសេសត្រូវ បានតែងតាំងដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ អាណត្តិគាហកៈពិសេស ត្រូវសុំណែនាំពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុមុន ពេលចូលរួមមហាសន្និបាតក្រុមហ៊ុនចំរុះ ។

ជំពូកទី ៥

អវសានប្បញ្ញត្តិ

មាត្រា ៥៩ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាដ៏ខ្ពង់ខ្ពស់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

បានបង្គំទូលថ្វាយ និងជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២

ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការនីតិសម្បទា

និងអភិវឌ្ឍន៍ និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ហត្ថលេខា

គាត ឈន់

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខា ហត្ថលេខា

នរោត្តម រណឫទ្ធិ ហ៊ុន សែន

II - ឯកសារគណៈរដ្ឋមន្ត្រី

១_អនុក្រឹត្យ

ភ្នំពេញ, ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ៣២ អនក្រ.បក

ស្តីពីការចាត់តាំង និង ការប្រព្រឹត្តទៅនៃប្រព័ន្ធ

សំរបសំរួលផ្ទៃក្នុង (Internal Coordination Network)

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ករត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រមលេខ ០១ សជ ៩៥ ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការផ្តល់សច្ចាប័នលើសន្ធិសញ្ញាមិត្តភាព និង សហប្រតិបត្តិការនៅអាស៊ី–អាគ្នេយ៍
- បានឃើញសំណើរបស់ព្រះរាជាណាចក្រកម្ពុជា សុំចូលជាផ្លូវការ ជាសមាជិកពេញសិទ្ធិរបស់ សមាគមបណ្តាប្រជាជាតិអាស៊ី–អាគ្នេយ៍ ចុះថ្ងៃទី ៣ ខែ មេសា ឆ្នាំ ១៩៩៦
- តាមសំណើរបស់រដ្ឋមន្ត្រីការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

សំរេច

មាត្រា ១ : បង្កើតប្រព័ន្ធសំរបសំរួលផ្ទៃក្នុង ដែលជាភាសាអង់គ្លេសហៅថា (Internal Coordination Network) សំរាប់ដឹកនាំ នឹងធ្វើការសំរបសំរួលសកម្មភាពរបស់

ក្រសួងគន្លឹះនានា បានទាន់ពេលវេលា និង មានប្រសិទ្ធភាពទាក់ទងដល់ការចូល និងបំពេញតួនាទីជាសមាជិកពេញសិទ្ធិ របស់អាស៊ាន នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២ : ប្រព័ន្ធសំរបសំរួលផ្ទៃក្នុងមានសមាសភាពដូចតទៅ :

១–សម្តេចក្រុមព្រះ នាយករដ្ឋមន្ត្រីទី ១	សហប្រធាន
២–សម្តេច នាយករដ្ឋមន្ត្រីទី ២	សហប្រធាន
៣–រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ	អនុប្រធានប្រចាំការ
៤–ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ	សមាជិក
៥–រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម	សមាជិក
៦–រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ	សមាជិក
៧–រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល	សមាជិក
៨–ទេសាភិបាលធនាគារជាតិ	សមាជិក
៩–តំណាងទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
១០–លេខាធិការដ្ឋានជាតិ អាស៊ាន–កម្ពុជា	លេខាធិការ

មាត្រា ៣ : ការអញ្ជើញប្រជុំ :

–សមាជិកទាំងឡាយនៃប្រព័ន្ធសំរបសំរួលផ្ទៃក្នុងចូលរួមប្រជុំតាមការអញ្ជើញរបស សហប្រធាន ។

–ក្នុងករណីចាំបាច់ សមាជិកទាំងឡាយនៃប្រព័ន្ធសំរបសំរួលផ្ទៃក្នុង ចូលរួមប្រជុំ តាមការអញ្ជើញ របស់អនុប្រធានប្រចាំការ ។

–តាមការចាំបាច់ ប្រធាន ឬ អនុប្រធានប្រចាំការ អាចអញ្ជើញប្រធានស្ថាប័ន ក្រសួងពាក់ព័ន្ធចូលរួមកិច្ចប្រជុំ ។

មាត្រា ៤ : ប្រព័ន្ធសំរបសំរួលផ្ទៃក្នុង មានសមត្ថកិច្ច និង ភារៈកិច្ចដូចតទៅ :

ក–សំរបសំរួលគោលនយោបាយជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងការធ្វើ សមាហរណកម្ម (Intergration) សេដ្ឋកិច្ចកម្ពុជាទៅក្នុងសេដ្ឋកិច្ចតំបន់ និង សេដ្ឋកិច្ចពិភពលោក ។

ខ–ណែនាំស្ថាប័នសំខាន់ៗ អំពីលំនាំសំរបសំរួល និងកិច្ចសហប្រតិបត្តិការជិតស្និទ ក្នុងការចូល អាស៊ាន, AFTA និងគំរោងផ្សេងៗទៀតរបស់អាស៊ានក្នុងគោល

បំណងទាញយកអោយបានជាអតិបរមា នូវផលប្រយោជន៍ពីការចូលអាស៊ាននិង ជៀសវាងនូវផលវិបាកអវិជ្ជមានទាំងឡាយ ។

គ–ពិនិត្យ និង សំរេច វិធានការជាក់ស្តែង កំណត់ការងារជាអទិភាពទាំងឡាយទាក់ទងដល់ការងារខាងលើ ។

ឃ–ធានាសំរបសំរួលទូទាំងប្រទេសអោយបានឆាប់រហ័សទាន់ពេលវេលា និង មានប្រសិទ្ធភាព ចំពោះរាល់កិច្ចការទាំងឡាយដែលពាក់ព័ន្ធនិងបញ្ហាអាស៊ាន ។

ង–តៀងគរជំនួយទាំងឡាយព្រមទាំងប្រមូលធនធានមនុស្ស និងថវិកាចាំបាច់ដើម្បីជួយឧបត្ថម្ភកិច្ចដំណើរការនៃការចូលជាសមាជិក ពេញសិទ្ធិរបស់អាស៊ានរបស់ព្រះរាជាណាចក្រកម្ពុជា ។

ច–តាមដានត្រួតពិនិត្យ និង វាយតម្លៃរាល់សកម្មភាពទាំងអស់ទាក់ទងនឹងសមាជិកភាព អាស៊ាន របស់ព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៥ : ប្រព័ន្ធសំរបសំរួលផ្ទៃក្នុង ប្រើប្រាស់លេខាធិការដ្ឋានជាតិអាស៊ាន–កម្ពុជា ស្ថិតក្នុងក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ជាសេនាធិការ និងជាយន្តការការងារប្រចាំថ្ងៃរបស់ខ្លួន ។

មាត្រា ៦ : លេខាធិការដ្ឋានជាតិអាស៊ាន–កម្ពុជា មានតួនាទី និងភារៈកិច្ចដូចតទៅ :

ក–ជាអ្នកសំរបសំរួលទូទាំងប្រទេស និង ជាអ្នកទំនាក់ទំនងអន្តរជាតិ ជាមួយនឹងលេខាធិការដ្ឋាន អាស៊ានព្រមទាំងលេខាធិការដ្ឋានជាតិ អាស៊ាន ទាំងអស់ ។

ខ–ជាសេនាធិការ និងជំនួយការជូនប្រព័ន្ធសំរបសំរួលផ្ទៃក្នុង ដើម្បីដោះស្រាយកិច្ចការទាំងអស់ ដែលពាក់ព័ន្ធបញ្ហាអាស៊ាន ហើយដែលទទួលបានការណែនាំពីប្រព័ន្ធសំរបសំរួលផ្ទៃក្នុង ។

មាត្រា ៧ : ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងនិងស្ថាប័នពាក់ព័ន្ធនានា ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

តួនាទី
និងភារកិច្ចនៃក្រសួងសំខាន់ៗ ដែលពាក់ព័ន្ធនឹងការងារអាស៊ាន
ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ក្រសួង
សេដ្ឋកិច្ច និង ហិរញ្ញវត្ថុនិង ក្រសួងពាណិជ្ជកម្ម

* * *

I–ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ :

ក្រសួងការបរទេសទទួលបន្ទុកនយោបាយរួម និងការទូតរបស់រាជរដ្ឋាភិបាល និងជាអ្នកសំរបសំរួលការងារអាស៊ាន ទូទាំងប្រទេសក្នុងឋានៈជាលេខាធិការដ្ឋានជាតិអាស៊ាន ។

តាមលំនាំរបស់អាស៊ាន កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី ក្រសួងការបរទេស ASEAN Minister al Meeting (AMM) ជាកិច្ចប្រជុំសំខាន់បំផុត តាមអាទិភាពនយោបាយបន្ទាប់ពីកិច្ចប្រជុំថ្នាក់ប្រមុខរដ្ឋ ឬប្រមុខរដ្ឋាភិបាល (ASEAN Summit) ។ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិមានតួនាទី និងភារៈកិច្ចធ្វើសេចក្ដីសំរេចនានា ផ្នែកនយោបាយជូនឬជួសរាជរដ្ឋាភិបាល ។ ក្នុងឋានៈនេះ រដ្ឋមន្ត្រី ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ធ្វើការសំរបសំរួលជាមួយរដ្ឋមន្ត្រីនានានៃក្រសួងជំនាញ ដែលពាក់ព័ន្ធនិងសកម្មភាពអាស៊ាន ។ បណ្ដារដ្ឋមន្ត្រីនៃក្រសួងជំនាញទាំងអោយនោះត្រូវធ្វើសេចក្ដីសំរេចទាំងឡាយដោយពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រី ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ដើម្បីរក្សាច្រកចេញ ចូលការទូតតែមួយគត (Diplomatic Channel) ។

តាមលំនាំរបស់អាស៊ាន មានតែងតាំងមន្ត្រីជាន់ខ្ពស់ម្នាក់ មានឈ្មោះថា Senior Offic al នៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដែលជាមន្ត្រីជាន់និរន្តភាព នៃ ការងារទាំងឡាយរបស់ក្រសួង និង ភាពអចិន្ត្រៃយ៍របស់ក្រសួង មានឋានៈខ្ពស់ជាងគេបំផុតក្នុងមុខងារសាធារណៈ (Senior Most Civil Servant) ហើយដែលមិនមែនជាតំណែងនយោបាយ (Political Appointee) ទេ គឺអគ្គលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ។

មន្ត្រីជាន់ខ្ពស់នេះ ទទួលបន្ទុកចូលរួមសន្និសីទមន្ត្រីជាន់ខ្ពស់ Senior Official Meeting (SOM) មានសិទ្ធិសំរេចក្នុងការចរចាផ្នែកបច្ចេកទេស ហើយបន្ទាប់មកដាក់ជូនមន្ត្រីការបរទេស និង សហប្រតិបត្តិ ការអន្តរជាតិ និង រាជរដ្ឋាភិបាលធ្វើការសំរេចផ្នែកនយោបាយ ។ ជារួមមន្ត្រី

ជាន់ខ្ពស់ផ្នែកនយោបាយ (SOM) ត្រៀមរៀបចំសន្និសីទថ្នាក់រដ្ឋមន្ត្រី មាន AMM ARF PMC និង [illegible] ជាដើម ។

ក្នុងក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ មានបង្កើតអគ្គនាយកដ្ឋានអាស៊ានមួយដឹកនាំដោយអគ្គនាយកមួយរូប ជំនួយការដោយអគ្គនាយករងពីររូប ។ អគ្គនាយកដ្ឋាននេះមានភារកិច្ចដូចតទៅ :

- ជាអ្នកសម្របសម្រួលការងារជាមួយ :
  - លេខាធិការដ្ឋានអាស៊ាននៅហ្សាការតា
  - លេខាធិការជាតិអាស៊ាននៃប្រទេសសមាជិកអាស៊ាន
  - អង្គភាពអាស៊ាន នៃក្រសួងនានា
- ជាលេខាធិការរបស់ប្រព័ន្ធសម្របសម្រួលផ្ទៃក្នុង (Internal Coordination Network) ដឹកនាំដោយ សម្តេចនាយករដ្ឋមន្ត្រី ទាំងពីរជាសហប្រធាន ។

II- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ :

ទទួលខុសត្រូវការងារនយោបាយសេដ្ឋកិច្ចរួមរបស់រាជរដ្ឋាភិបាល និង រៀបចំថវិកាជាតិសំរាប់សកម្មភាពអាស៊ាន ។

នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានមន្ត្រីសេដ្ឋកិច្ចជាន់ខ្ពស់មួយរូបដែលជាមន្ត្រីរាជការជានាទិនុត្តភាព នៃការងារទាំងឡាយរបស់ក្រសួង និងភាពអចិន្ត្រៃយ៍របស់ក្រសួងមានឋានៈខ្ពស់បំផុតនៅក្នុងមុខងារសាធារណៈ ដូចជាអគ្គលេខាធិការក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិដែរ ។ មន្ត្រីរូបនេះជាអ្នកឯកទេសខាងការងារសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលហើយជាអ្នកមានសិទ្ធិសំរេចផ្នែកបច្ចេកទេសក្នុងអង្គប្រជុំ និងការចរចាវិស័យជំនាញសេដ្ឋកិច្ចនានាដូចជា SEOM ជាដើម ហើយបន្ទាប់មកត្រូវដាក់ជូនរដ្ឋមន្ត្រីជំនាញ និង រាជរដ្ឋាភិបាលសំរេចផ្នែកនយោបាយ ។

ទន្ទឹមនឹងនេះ នៅក្នុងក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ មានបង្កើតនាយកដ្ឋានអាស៊ានមួយ ។ ក្នុងក្រសួងនេះដែរមានបង្កើតអង្គភាព AFTA មួយដែលមានការចូលរួមពីមន្ត្រីនៃក្រសួងពាក់ព័ន្ធនានា ។ អង្គភាពនេះមានភារកិច្ចសំខាន់ក្នុងការពិភាក្សាលើការកាត់បន្ថយពន្ធគយ លើទំនិញនាំចេញ នាំចូល ការបញ្ចូលទំនិញក្នុងបញ្ជីទាំងឡាយ ដូចមានចែងនៅក្នុង CEPT Scheme ជាមួយប្រទេសដែលមានសមាជិកអាស៊ាន និង លេខាធិការដ្ឋានអាស៊ាន ។ នាយកដ្ឋាននេះត្រូវសហការ យ៉ាងជិតស្និទ្ធជាមួយក្រសួងពាណិជ្ជកម្ម ក្នុងការកំណត់មុខទំនិញនានា ។ ក្រសួងសេដ្ឋកិច្ច

និង ហិរញ្ញវត្ថុ ក៏មានភារៈកិច្ចតាមដានមុខសញ្ញាសហប្រតិបត្តិការថ្មីៗ របស់អាស៊ាន ដូចខាង ផ្នែកសេវាកម្ម (Services) និងតំបន់វិនិយោគសេរីអាស៊ាន ASEAN Free Investment Area-AFIA) ជាដើម ។

III– ក្រសួងពាណិជ្ជកម្ម : ទទួលខុសត្រូវលើវិស័យនយោបាយពាណិជ្ជកម្មក្រៅប្រទេស ។

នៅក្រសួងនេះ ក៏ត្រូវបង្កើតនាយកដ្ឋានអាស៊ានមួយដែរ ។ នាយកដ្ឋាននេះត្រូវសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការកំណត់មុខទំនិញក្នុង CEPT Scheme ។ ក្រសួងពាណិជ្ជកម្មជាអ្នកចេញ Certificate of Origin (CO) ចូលរួមយ៉ាងសកម្មនៅក្នុងបញ្ហានានា ទាក់ទងដល់កម្មសិទ្ធិបញ្ញា (Intellectual property) ការត្រួតពិនិត្យគុណភាពទំនិញ (Quality control) អាជ្ញាកណ្តាល (arbitration) ការផ្តល់ភាពអនុគ្រោះបំផុត (MFN) និងភាពអនុគ្រោះដូចគ្នានឹងក្រុមហ៊ុនជាតិកម្ពុជា (National treatment) ដល់ក្រុមហ៊ុននានា នៃបណ្តាប្រទេសជាសមាជិកអាស៊ាន ។

ទន្ទឹមនឹងនេះ ក្រសួងពាណិជ្ជកម្មត្រូវតែងតាំងមន្ត្រីជាន់ខ្ពស់មួយរូបជា Deputy SEOM ។

VI– ក្រសួងនិងស្ថាប័នពាក់ព័ន្ធដទៃទៀត :

ត្រូវបង្កើតអង្គភាពអាស៊ានមួយថ្នាក់ស្មើការិយាល័យហៅឈ្មោះជា ASEAN Unit ដើម្បីវិភាគ និងគ្រប់គ្រងការងារអាស៊ាននានា ដែលទាក់ទិនផ្ទាល់ទៅនឹងសមត្ថកិច្ចនៃក្រសួង ឬស្ថាប័នខ្លួន។

ក្រសួងទាំងនោះចាំបាច់ធ្វើការសំរបសំរួល និង សហប្រតិបត្តិការជិតស្និទ្ធជានិរន្តជាមួយក្រសួងពាណិជ្ជកម្មក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ព្រមទាំងជាមួយលេខាធិការដ្ឋានជាតិអាស៊ាន ដែលស្ថិតនៅក្នុងក្រសួង ការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ។

ភ្នំពេញ, ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ១៩៩៦

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ មិថុនា ១៩៩៦

អនុក្រឹត្យលេខ ១១៧ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

សំរេច

មាត្រា ១ : តែងតាំង :

១-លោក **ហែម ហេង** អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការជាតិ ជាអគ្គនាយករងអាស៊ានទទួលបន្ទុកសេដ្ឋកិច្ចមានឋានៈស្មើប្រធាននាយកដ្ឋាន

២-លោក **កែម មង្គល** ទីប្រឹក្សារដ្ឋមន្ត្រី ជាប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ

៣-លោក **ហ៊ឹម ស្មៀរ** ទីប្រឹក្សារដ្ឋមន្ត្រី ជាប្រធាននាយកដ្ឋានពិធីការ

៤-លោក **អេង យ៉េត** អនុប្រធាននាយកដ្ឋាន អឺរ៉ុប ជាប្រធាននាយកដ្ឋានអាមេរិក

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ

នៃស្ថាប័នពាក់ព័ន្ធ និងមន្ត្រីមាននាមក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខា និងត្រា ហត្ថលេខានិងត្រា

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១១៨ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តបន្ទាយមានជ័យ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយមាសស្ថាបនាជាតិជូនចំពោះលោកឧត្តមសេនីយ៍ចៅ **សម្បត្តិ** ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ចំនួន ៤០.០០០$US សំរាប់កសាងស្ពានមួយកន្លែងមានបណ្តោយ ៨៥ ម៉ែត្រនៅក្នុង ឃុំព្រះពន្លា ស្រុកសេរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបន្ទាយមានជ័យត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខា និងត្រា ហត្ថលេខានិងត្រា

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១១៩ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងកការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពង់ស្ពឺ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយ « មាស » ស្ថាបនាជាតិ ជូនចំពោះលោក និង អ្នកស្រី HUANG MUKUN ប្រធានក្រុមហ៊ុន CHIENTOR Company ដែលបានបរិច្ចាគថវិកាចំនួន ១០.៥០០ ដុល្លារអាមេរិក សំរាប់សាងសង់អាគារសិក្សា ០១ ខ្នង នៅក្នុងវត្តសាឡូង ឃុំវល្លិស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាល ខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១២០ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយ ប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តពោធិសាត់

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយមាស ស្ថាបនាជាតិ ជូនចំពោះលោកស្រី **នុច ហ៊ាម** ប្រធាន ក្រុមហ៊ុន ASIA GOLDEN DRAGON CORPORATION ដែលបានជួយ ឧបត្ថម្ភដល់ ខេត្តពោធិសាត់ នូវម៉ាស៊ីនបូមទឹក ៤៤ គ្រឿង សាលារៀនមួយខ្នង និង

អង្ករ ០៧ តោន សំរាប់បំរើដល់ការខ្វះខាតរបស់ប្រជារាស្ត្រ មានតំលៃគិតជាទឹកប្រាក់ ២២.២៦០ $ US ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាល ខេត្តពោធិសាត់ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និងត្រា	ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១២១ អនក្រ.គគ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយ ប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយមាស ស្ថាបនាជាតិ ជូនចំពោះកញ្ញា **អ៊ូ អ៊ីម៉ាំ** ធ្វើការនៅ ក្រុមហ៊ុនសាំងឡេងអន្តរជាតិ ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួនចំនួន ២៥.០០០ $US

សំរាប់ស្ពានថ្នល់ប្រវែង ២.៥០០ ម៉ែត្រ ដោយចាក់ដីក្រាលគ្រួសក្របាម ដាក់លូ ស្ថិតនៅចន្លោះសង្កាត់ ក្រាំងធ្នង់ ដល់សង្កាត់គោករកាក្នុងរាជធានីភ្នំពេញ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបាន លទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១២២ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយ ប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី ២

សំរេច

ប្រការ ១ : ត្រូវបានប្រគល់មេដាយ ស្ថាបនាជាតិ ជូនចំពោះសប្បុរសជនដែលមានសទ្ធាជ្រះថ្លា បានបរិច្ចាគថវិកាផ្ទាល់ខ្លួន សំរាប់ជួយកសាង វិទ្យាល័យ ទេពប្រណម្យ ក្នុងឃុំ វិហារហ្លួង ស្រុកពញាឮ ខេត្តកណ្តាល ដូចមានរាយនាមតាមលំដាប់ថ្នាក់ខាងក្រោម÷

ខ_មេដាយមាស :

១_លោក **ផៃ ហុកឈួន** និងអ្នកស្រី **អ៊ុង ស៊ូស្រ៊ន** បរិច្ចាគថវិកា ១២៥.០០០$US

២_លោក **ផៃ ខួន** និងអ្នកស្រី **ឆាំង ស៊ារ៉ែម** បរិច្ចាគថវិកា ២៣.០០០$US

ខ_មេដាយសំរិទ្ធ :

៣_លោកជំទាវ **ម៉ែន សំអន** បរិច្ចាគថវិកា ៣.៥០០$US

២_លោក **ទៀម ឆិត** និងអ្នកស្រី **អ៊ុន សារ៉ា** បរិច្ចាគថវិកា ០.៥០០$US

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខា និងត្រា ហត្ថលេខា និងត្រា

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ១៩៩៦

២_សេចក្តីសំរេច

សេចក្តីសំរេចលេខ ២៤ សសរ

ស្តីពីការបង្កើតគណៈកម្មការដឹកជញ្ជូនទំនិញពិសេស

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- តាមសំណើរបស់ឯកឧត្តមអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

សំរេច

ប្រការ ១ : បង្កើតគណៈកម្មការចំរុះមួយ ទទួលបន្ទុកដឹកទំនិញពិសេសសំរាប់ធនាគារជាតិ នៃកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម :

១–តំណាងក្រសួងមហាផ្ទៃ ជាប្រធាន

២–តំណាងក្រសួងការពារជាតិ ជាអនុប្រធានទទួលបន្ទុកការពារក្នុងការដឹកជញ្ជូន

៣–តំណាងធនាគារជាតិនៃកម្ពុជា ជាសមាជិក

ប្រការ ២ : គណៈកម្មការចំរុះនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ដើម្បីពិភាក្សាបែងចែកភារកិច្ចដឹកជញ្ជូនទំនិញពិសេស ។

ប្រការ ៣ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ និង អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១
ព្រះហស្តលេខា និងត្រា
នរោត្តម រណប្ញទ្ធិ

នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខានិងត្រា
ហ៊ុន សែន

* * *

III - ការងារបណ្ដាក្រសួង

១_ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៦

ប្រកាសលេខ ២០០ ប្រក.សហវ

ស្ដីពីការប្រើប្រាស់ជំនួយទូទាត់ថវិកា និង មូលនិធិបដិភាគ

ក្នុងកិច្ចប្រតិបត្តិការពិសេស

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** លេខ ០១ នស ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** លេខ ១០៩៤/៨៣ នស ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពនៃរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃ គណៈរដ្ឋមន្ត្រី
- បានឃើញច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើប្រាស់ដោយ ព្រះរាជក្រម នស.រកម ០១៩៦-១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញព្រះរាជក្រម លេខ ០១ នស ៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ គ្រប់គ្រងច្បាប់ ហិរញ្ញវត្ថុ និង ប្រព័ន្ធថវិកា
- បានឃើញព្រះរាជក្រមលេខ ១២៩៥ នស ០៧ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៥ ស្ដីពីច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ១៩៩៦

- បានឃើញអនុក្រឹត្យលេខ ៨១ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្ដីពីការត្រួតពិនិត្យហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យ លេខ ៨២ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្ដីពីបទបញ្ញាទូទៅលើគណនេយ្យសាធារណៈ
- យោងតាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សម្រេច

ប្រការ ១ : កិច្ចប្រតិបត្តិការចំណាយ ក្នុងក្របខ័ណ្ឌថវិការដ្ឋដែលធ្វើហិរញ្ញប្បទានដោយជំនួយបរទេស ឬដោយមូលនិធិបដិភាគក្នុងកិច្ចប្រតិបត្តិការពិសេស ត្រូវអនុវត្តនិងត្រួតពិនិត្យតាមបទបញ្ញត្តិទាំងឡាយនៃ ប្រកាសនេះ ។

ប្រការ ២ : សំណើការសន្យាចំណាយទាំងឡាយរបស់ក្រសួងនានាត្រូវផ្ញើផ្ទាល់មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ នាយកដ្ឋានគ្រប់គ្រងទុនវិនិយោគសាធារណៈ ទទួលខុសត្រូវក្នុងការពិនិត្យ និង ធានាអោយមានភាពស្របគ្នានៃគំរោងចំណាយ និង កម្មវិធីប្រើប្រាស់ដែលបានព្រមព្រៀងដោយអ្នកផ្ដល់មូលនិធិ ។

ប្រការ ៣ : ការសន្យាចំណាយត្រូវប្រព្រឹត្តឡើងអោយស្របគ្នា តាមនីតិវិធីលទ្ធកម្មទៅតាមទំហំទឹកប្រាក់ដែលបានកំណត់ដោយបទបញ្ញាទាំងឡាយនៃលទ្ធកម្មសាធារណៈ ។

ប្រការ ៤ : អាណត្តិបើកប្រាក់ ដែលធ្វើឡើងដោយអាណាប័ក (ក្រសួងបច្ចេកទេស គ្រប់គ្រងគំរោង) ត្រូវផ្ញើជូនទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានហិរញ្ញវត្ថុ ក្រៅប្រទេស) ដើម្បីធ្វើការទូទាត់ ដោយផ្អែកតាមសក្ខីប័ត្រចំណាយនានា ។

ប្រការ ៥ : សក្ខីប័ត្រចំណាយទាំងឡាយ ត្រូវបានបង្កើតឡើងតាមលទ្ធកម្មនានា តាមកិច្ចសន្យាប្រគល់សំភារៈ ឬ ការងារតាមវិក្កយប័ត្រ និង តាមឯកសារផ្សេងៗទៀត ជាតឹកតាងនៃគណនេយ្យ ។

ប្រការ ៦ : នាយកដ្ឋានគ្រប់គ្រងវិនិយោគសាធារណៈ ត្រូវធានានូវភាពត្រឹមត្រូវនៃចំណាយ និងការសន្យា ដែលបានចែងក្នុងប្រការ២ ខាងលើ ។

ប្រការ ៧ : ការទូទាត់ចំណាយត្រូវអនុវត្តដោយផ្ទាល់អោយអ្នកផ្គត់ផ្គង់ ឬអោយអ្នកប្រគល់សំភារៈ ឬ ការងារតាមមូលប្បទានប័ត្រ ឬ តាមដីកាបង្វែរដែលរៀបចំឡើងដោយនាយកដ្ឋានហិរញ្ញវត្ថុក្រៅប្រទេស ដើម្បីជូនចុះហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិង

ហិរញ្ញវត្ថុ ឬ ដោយអ្នកតំណាងលើគណនីពិសេស ដែលបើកក្នុងនាមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅធនាគារជាតិនៃកម្ពុជា ។

ប្រការ ៨ : នាយកដ្ឋានហិរញ្ញវត្ថុក្រៅប្រទេស ត្រូវគ្រប់គ្រងនិងកាន់បញ្ជីគណនេយ្យជំនួយជាក្រោមនូវកិច្ចប្រតិបត្តិការចំណូល និង ចំណាយដែលបានអនុវត្តលើរាល់គណនីពិសេសនៃជំនួយទ្រទ្រង់ថវិកា និង មូលនីធិបដិភាគ ។

ប្រការ ៩ : ការត្រួតពិនិត្យពេលក្រោយការអនុវត្តន៍ការងារ ត្រូវធ្វើឡើងដោយមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដែលនៅអមក្រសួងបច្ចេកទេសដោយមានការចូលរួមពីតំណាងនាយកដ្ឋានគ្រប់គ្រងវិនិយោគស្ថាបនាមូលដ្ឋានផង ។ របាយការណ៍ទាំងអស់របស់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវចំលង ជូនទៅអោយនាយកដ្ឋានគ្រប់គ្រងវិនិយោគស្ថាបនាមូលដ្ឋាន ។

ប្រការ១០: នាយកដ្ឋានគ្រប់គ្រងវិនិយោគស្ថាបនាមូលដ្ឋាន ត្រូវទទួលបន្ទុករៀបចំរបាយការណ៍ដើម្បីបង្ហាញជូនអ្នកផ្តល់មូលនីធិនៅពេលបញ្ចប់ប្រតិបត្តិការកម្មវិធី ។

ប្រការ១១: ការប្រើប្រាស់មូលនីធិបដិភាគដែលបានមកពីជំនួយអន្តរជាតិ ហើយដែលបានផ្ទេរចូលក្រសួងនានា រហូតដល់កាលបរិច្ឆេទនៃការចេញប្រកាសនេះនឹងត្រូវធ្វើការត្រួតពិនិត្យដល់ទីកន្លែង និងផ្អែកលើលិខិតគតិយុត្តនានាដោយក្រុមអធិការកិច្ចហិរញ្ញវត្ថុ។ របាយការណ៍នៃការត្រួតពិនិត្យហិរញ្ញវត្ថុនេះ ត្រូវដាក់ជូនប្រធាននាយកដ្ឋានគ្រប់គ្រងវិនិយោគស្ថាបនាមូលដ្ឋាន ។

ប្រការ១២: នាយកខុទ្ទកាល័យ ប្រធានមន្ទីរ និងប្រធាននាយកដ្ឋានពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា និង ត្រា

គាត ឈន់

* * *

២_ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

ប្រកាសលេខ ៤០៦ ឧក. ប្រក ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៩៨៦

ប្រការ ១ : អនុញ្ញាតអោយលោក **ឈួន លីម** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណបណ្ណលេខ ០០៧៥២៥ ព.វ ចុះថ្ងៃទី ២២-៥-១៩៨៦ អាស័យដ្ឋានបច្ចុប្បន្ន ភូមិព្រៃកខ្សាយ ឃុំព្រៃកខ្សាយ «ក» ស្រុក ពាមរក៍ ខេត្តព្រៃវែង បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១២០សេះ នៅក្នុង ទីតាំងភូមិ ស្ទឹងស្លូត ឃុំអ្នកលឿង ស្រុកពាមរក៍ ខេត្តព្រៃវែង ។

ប្រការ ២ : លោក **ឈួន លីម** ត្រូវចាប់ផ្ដើមដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៤០៧ ឧក. ប្រក ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៩៨៦

ប្រការ ១ : អនុញ្ញាតអោយលោក **ទឹមអ៊ុំ យ៉ុន** ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណបណ្ណលេខ ០០៣០៧៩ព.ស ចុះថ្ងៃទី ២០–៦–១៩៨៦ អាស័យដ្ឋានបច្ចុប្បន្ន ភូមិត្រពាំងជង ឃុំត្រពាំងជង ខេត្តពោធិសាត់ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៤០ សេះ នៅក្នុងទីតាំងភូមិកោះកែវ ឃុំត្រពាំងជង ស្រុកបាកាន ស្រុកបាកាន ខេត្តពោធិសាត់ ។

ប្រការ ២ : លោក **អ៊ែម យ៉ុន** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំ ការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៤០៨ ឧក.ប្រក ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុន ខូលីធី តេក្សស្ទីល ខូអែលធីឌី(QUALITY TEXTILES CO.LTD) តំណាងដោយលោក SEOW FUI CHEONG សញ្ជាតិម៉ាឡេស៊ី អាយុ៥២ ឆ្នាំភេទប្រុស អាស័យដ្ឋានលេខ ២៣ JALAN BUNGA RAYAMELAKA MALAYSIA កាន់លិខិតឆ្លងដែនលេខ A5922907 ចុះថ្ងៃទី ០៩-០២-១៩៩៣ បង្កើត «រោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញ» ដែលមានឈ្មោះ «រោងចក្រ កាត់ដេរសំលៀកបំពាក់ ខូលីធី តេក្សស្ទីល » មានទីតាំងស្ថិតនៅផ្ទះលេខ ២១០ ផ្លូវលេខ ២៤៥ សង្កាត់ទំនប់ទឹក ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ។

ប្រការ ២ : ការបង្កើតរោងចក្រនេះត្រូវធ្វើទៅតាមប្លង់ និង គំរោងសិក្សាលទ្ធភាពបង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់ដែលបានតំកល់ទុក នៅក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល ។

ប្រការ ៣ : ក្នុងកិច្ចដំណើរការក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និងគុណភាព ផលិតផល ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែជូនក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ។

ប្រការ ៤ : រោងចក្រនេះ ត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផល «សំលៀកបំពាក់» ទៅតាមគំរូដែល តំកល់ទុកនៅក្រសួងឧស្សាហកម្មរ៉ែនិងថាមពល ។

ប្រការ ៥ : ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសប្រការណាមួយដែលបានចែងខាងលើប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៤០៩ ឧក.ប្រក ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៩៩៦

ប្រការ ១ : អ្នកស្រី **សេ សទ្ធាន** ត្រូវបានអនុញ្ញាតអោយបន្តដំណើរការសិប្បកម្មផលិតទឹកស៊ីអ៊ីវសញ្ញា «រូបភ្នំពីរ» ឡើងវិញ ចាប់តាំងពីថ្ងៃដែលបានចុះហត្ថលេខានេះតទៅ ។

ប្រការ ២ : អ្នកស្រី **សេ សទ្ធាន** ត្រូវបានអនុញ្ញាតអោយផលិតបន្ថែមនូវមុខផលិតផលទឹកត្រី «ភ្នំពីរ រូបមាន់ គក់ពីរ» ទឹកជ្រក់ម្ទេសជូរអែម «រូបផ្លែម្ទេស ៦ ផ្លែ» ទឹកស៊ីអ៊ីវម៉ាហ្ស៊ីពិសេស «រូបផ្លែពោត» ទឹកស៊ីអ៊ីវម៉ាហ្ស៊ីរូបស្ពៃធំ «រូបស្ពៃធំ» ទឹកត្រី ត្រីបង្កងព័ទ្ធភ្នំ «រូបត្រីបង្កងព័ទ្ធភ្នំ» និង ទឹកស៊ីអ៊ីវម៉ាហ្ស៊ី «រូបសំពៅ» ស្របតាមគំរូសញ្ញាសំគាល់ដែលបាន តំកល់ទុកនៅក្រសួងឧស្សាហកម្មរ៉ែនិងថាមពល ។

ប្រការ ៣ : រាល់ប្រការដែលមានចែងក្នុងប្រកាសលេខ ៣៨៥ ឧក.ប្រក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩៣ របស់ក្រសួងឧស្សាហកម្មរ៉ែនិងថាមពល នៅមានតំលៃជាធរមានបញ្ញត្តិដដែល ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ពូ សុធីរៈ

* * *

ប្រកាសលេខ ៤១០ ឧក.ប្រក ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **ឃឿត ខាន់** ជនជាតិខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៦៨២៥៣ ប.ប ចុះថ្ងៃទី ២៩-៧-៨៧ អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី

១៨ ទួលល្មៀង ឃុំអូរដំបង ស្រុកសង្កែ ខេត្តបាត់ដំបង បើកដំណើរការរោង ម៉ាស៊ីនកិនស្រូវ កំលាំង ៦០ សេះ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **ឃឿន ខាន់** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំង ដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាង តិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់នេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើ ពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើស ច្បាប់ ឬ បង្កអោយមានការ ប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៤១១ ផក.ប្រក ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៩៨៦

ប្រការ ១ : អនុញ្ញាតអោយលោក **ចៅ ម៉ី** ជនជាតិខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណ ប័ណ្ណលេខ ១៣៧៦៥៨ ប.ប ចុះថ្ងៃទី ០៨–១២–៨៨ អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី ៣ ភូមិតាក្រាម ឃុំតាក្រាម ស្រុកបាណន់ ខេត្តបាត់ដំបង បើកដំណើរការរោង ម៉ាស៊ីនកិនស្រូវ កំលាំង ៦០ សេះ នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **ចៅ ម៉ី** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម–អាជីវកម្ម លើទីតាំងដូចបាន កំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់នេះ ម្ចាស់មូលដ្ឋានត្រូវ ធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើស ច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

អ៊ិត ប្រាំង

* * *

៣_ ទីស្ដីការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៩៩៦

ប្រកាសលេខ ១៨៤/៩៦ ព.ម បល.ប្រក

ស្ដីពីការតែងតាំងមន្ត្រីរាជការ

* * *

រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើច្បាប់ស្ដីពីការ បង្កើតក្រសួងពតិមាន
- តាមការចាំបាច់របស់ក្រសួង
- ពិនិត្យលើលក្ខណៈសម្បត្តិ និង សមត្ថភាពរបស់មន្ត្រីរាជការ

សំរេច

ប្រការ ១ : តែងតាំងមន្ត្រីរាជការចំនួន ០២រូប ជាថ្នាក់អនុប្រធាននាយកដ្ឋាន នាយកដ្ឋានផែនការគណនេយ្យ ហិរញ្ញវត្ថុ នៃអគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ ដូចមានរាយនាមខាង ក្រោមនេះ ÷

១– លោក **ឌុត សារុន** អនុប្រធាននាយកដ្ឋាន ទទួលផែនការ ហិរញ្ញវត្ថុ និង ចំណូលសាធារណៈ

២– លោក **សាន ឃួត** អនុប្រធាននាយកដ្ឋាន ទទួលគណនេយ្យ

ប្រការ ២ : លោកនាយកខុទ្ទកាល័យ ,លោកអគ្គនាយក រដ្ឋបាល និង ហិរញ្ញវត្ថុ , លោកអគ្គនាយក បណ្ណាអគ្គនាយកដ្ឋាន ,លោកប្រធាននាយកដ្ឋាន រដ្ឋបាលបុគ្គលិក លោកប្រធាននាយកដ្ឋានផែនការ គណនេយ្យ ហិរញ្ញវត្ថុ និង អស់លោកក្នុងប្រការ ១ ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះ ហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

អៀង មូលី

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៩៩៦

ប្រកាសលេខ ១៨៦/៩៦ ពម មពប្រក

អនុញ្ញាតអោយកាសែតឈ្មោះ «សម្លេងសច្ចះ»

បោះពុម្ពចែកផ្សាយ

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជាជំពូក ៣ មាត្រាទី ៤១
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីរបបសារពត៌មាន នៃ ព្រះរាជាណាចក្រកម្ពុជាដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នស.រកម ០៨៩៥-០៧ ចុះថ្ងៃទី ០១ ខែ កញ្ញា ១៩៩៥
- បានឃើញសំណើសុំបោះពុម្ពកាសែត « **សម្លេងសច្ចះ** » ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៦

សំរេច

ប្រការ ១ : អនុញ្ញាតអោយកាសែតឈ្មោះ «សម្លេងសច្ចះ» បោះពុម្ពចែកផ្សាយដោយមានលោក កែវ ចាន់ឌួង ជាចាងហ្វាងការផ្សាយ ។ ទីស្នាក់ការលេខ ៩១អឺ១ ផ្លូវ ១៣៩

សង្កាត់ វាលវង់ ខណ្ឌ ៧មករា ក្រុងភ្នំពេញ ។ ក្នុងករណីមានការផ្លាស់ប្តូរចំណុច ណាមួយក្នុង អត្តសញ្ញាណនៃកាសែតរបស់ខ្លួន ត្រូវជូនដំណឹងជាមុន ០៥ ថ្ងៃ មកក្រសួងពត៌មាន ដើម្បី រង់ចាំសេចក្តីសំរេចជាថ្មី ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពចែកផ្សាយត្រូវគោរពតាមគោលការណ៍ក្រមសីលធម៌ អ្នកកាសែតនិង ឈរលើស្មារតីទទួលខុសត្រូវខ្ពស់ក្នុងវិជ្ជាជីវៈរបស់ខ្លួន ។ ខ្លឹមសារអត្ថបទត្រូវអនុវត្តន៍អោយបាន សមស្របតាមទំនៀមទំលាប់ប្រពៃណីល្អ និង ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា រួចស្នើប្រគល់ កាសែតចំនួន ០៦ ច្បាប់ រៀងរាល់លេខចេញផ្សាយមកតំកល់ទុកឯកសារនៅក្រសួងពត៌មាន ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តល្មើសអំពីសេចក្តីដូចមានចែងក្នុងប្រការ ១ និង ប្រការ ២ ខាងលើ សាមីខ្លួនត្រូវ ទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៤ : អគ្គនាយក រដ្ឋបាល និង ហិរញ្ញវត្ថុ–នាយកមណ្ឌលពត៌មាន និង លោកចាងហ្វាងកាសែត «សម្លេងសច្ចៈ» ត្រូវអនុវត្តន៍នូវប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះមានប្រសិទ្ធភាពរយៈពេល២ឆ្នាំ និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ
ហត្ថលេខា និងត្រា
ខៀវ កាញារីទ្ធ

រាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៩៩៦

ប្រកាសលេខ ១៨៧/៩៦ ពម.មពប្រក

អនុញ្ញាតអោយកាសែតឈ្មោះ «សម្លេងរាស្ត្រខ្មែរ»

បោះពុម្ពចែកផ្សាយ

* * *

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ជំពូក ៣ មាត្រាទី ៤១

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ ស្តីពីរបបសារពត៌មាន នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើតាមព្រះព្រះរាជក្រមលេខ នស.រកម ០៨៩៥-០៧ ចុះថ្ងៃទី ០១ កញ្ញា ១៩៩៥
- បានឃើញសំណើសុំបោះពុម្ពកាសែត « **សម្លេងរាស្ត្រខ្មែរ** » ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៦

សំរេច

ប្រការ ១ : អនុញ្ញាតអោយកាសែតឈ្មោះ" សម្លេងរាស្ត្រខ្មែរ" បោះពុម្ពចែកផ្សាយដោយមាន លោក **ឯក សុខ អ៊ឹម** ជាចាងហ្វាងការផ្សាយ ។ ទីស្នាក់ការលេខ ១៧២អឺ២ ផ្លូវមុន្នីរ៉េត ខ័ណ្ឌចំការមន ។ ក្នុងករណីមានការផ្លាស់ប្តូរចំណុចណាមួយក្នុង អត្តសញ្ញាណ នៃកាសែតរបស់ខ្លួន ត្រូវជូនដំណឹង ជាមុន ០៥ ថ្ងៃមកក្រសួងពត៌មាន ដើម្បីរង់ចាំសេចក្តីសំរេចជាថ្មី ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពចែកផ្សាយ ត្រូវគោរពតាមគោលការណ៍ក្រមសីលធម៌ អ្នកកាសែត និង ឈរលើស្មារតីទទួលខុសត្រូវខ្ពស់ក្នុងវិជ្ជាជីវៈរបស់ខ្លួន ។ ខ្លឹមសារអត្ថបទត្រូវអនុវត្តន៍អោយបាន សមស្របតាមទំនៀមទំលាប់ប្រពៃណីល្អ និង ច្បាប់នៃ ព្រះរាជាណាចក្រកម្ពុជារួចស្នើប្រគល់ កាសែតចំនួន ០៦ ច្បាប់រៀងរាល់លេខចេញ ផ្សាយមកតំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តល្មើសអំពីសេចក្តីដូចមានចែងក្នុងប្រការ ១ និង ប្រការ២ ខាងលើ សាម៉ីខ្លួន ត្រូវ ទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៤ : អគ្គនាយក រដ្ឋបាល និង ហិរញ្ញវត្ថុ នាយកមណ្ឌលពត៌មាន និង លោកចាងហ្វាងកាសែត" សម្លេងរាស្ត្រខ្មែរ " ត្រូវអនុវត្តន៍នូវប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះមានប្រសិទ្ធភាពរយៈពេល ២ ឆ្នាំ និង ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៩៩៦

ប្រកាសលេខ : ១៩០/៩៦ ពម.បលប្រក

ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

រដ្ឋមន្ត្រីក្រសួងពតិមាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យព្រះករុណា ព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងពតិមាន
- តាមការចាំបាច់របស់ក្រសួង
- ពិនិត្យលើលក្ខណៈសម្បត្តិ និង សមត្ថភាពមន្ត្រីរាជការ

សំរេច

ប្រការ ១ : តែងតាំងមន្ត្រីរាជការចំនួន ២ រូប ជាថ្នាក់អនុប្រធាននាយកដ្ឋាន នាយកដ្ឋានរដ្ឋបាល បុគ្គលិក នៃអគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ ដូចមានរាយនាមខាងក្រោមនេះ ÷

- លោក **សោម ប៊ុរ៉ា** ជាអនុប្រធាននាយកដ្ឋាន ទទួលបុគ្គលិក
- លោក **ឈុំ សុជាតិ** ជាអនុប្រធាននាយកដ្ឋាន ទទួលរដ្ឋបាល

ប្រការ ២ : លោកនាយខុទ្ទកាល័យ លោកអគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ លោកអគ្គនាយក បណ្ដាអគ្គនាយកដ្ឋាន លោកប្រធាននាយកដ្ឋានរដ្ឋបាល បុគ្គលិក លោកប្រធាននាយក ផែនការគណនេយ្យ និងហិញ្ញវត្ថុ និងអស់លោក ក្នុងប្រការ ១ ត្រូវអនុវត្តន៍តាម ប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

អៀង មូលី

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៩៩៦

ប្រកាសលេខ : ១៩១/៩៦ ពម.មពប្រក

អនុញ្ញាតអោយលោក កូហ្ស៊ីតេហ៊ីរ៉ូកា ប្រធានអង្គការ ជំនួយជប៉ុន បោះពុម្ពចែកផ្សាយបន្ថែមនូវសៀវភៅ និង ផ្ទាំងរូបភាព

* * *

រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ជំពូក ៣ មាត្រាទី ៤១
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្ដីពីរបបសារពត៌មាន នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើតាម ព្រះរាជក្រមលេខ នស.រកម ០៨៩៥–០៧ ចុះថ្ងៃទី ០១ កញ្ញា ១៩៩៥ ។
- បានឃើញសំណើសុំបោះពុម្ពលើកទី ៣ នូវសៀវភៅ និងផ្ទាំងរូបភាព ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៩៦ របស់អង្គការជំនួយសូត្តូស៊ូជប៉ុន ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយលោក **កូ ហ្ស៊ែតស៊ូរ៉ា** ប្រធានអង្គការជំនួយ សូតូស៊ូជប៉ុន បោះពុម្ពចែកផ្សាយ បន្ថែមនូវសៀវភៅ និងផ្ទាំងរូបភាព ដែលមានឈ្មោះដូចខាងក្រោមនេះ ÷

I– សៀវភៅរូបភាព :

១– រឿងជាតិខ្លាធំ
២– រឿង ពស់កេងកង
៣– រឿង ត្បាតចោកដីរ
៤– រឿង មាយាស្រ្តី
៥– រឿង សត្វបីសត្វធ្វើជាស្តេច
៦– រឿង កំណើតរន្ទះ
៧– រឿងមហាឬសីប្រោសខ្លា
៨– រឿងអន្ទង់វែង ផ្ទាំងវែង
៩– រឿង ពានរល្ងង់មកុដ
១០– រឿង ចៅតប់ប្រមល់

II-ផ្ទាំងរូបភាព : ១– ចៅអាចម៍សេះ ២– រឿង បុរសជីកក្តាម

ក្នុងករណីមានការផ្លាស់ប្តូរ នូវចំណុចណាមួយក្នុងអត្ថសញ្ញាណនៃសៀវភៅ និងផ្ទាំងរូបភាព របស់ខ្លួន ត្រូវជូនដំណឹងជាមុន ៥ ថ្ងៃ មកក្រសួងពត៌មាន ដើម្បីរង់ចាំសេចក្តីសំរេចជាថ្មី ។

ប្រការ ២ : ខ្លឹមសារអត្ថបទ និង សកម្មភាពផ្សព្វផ្សាយ មិនត្រូវអោយប្រាស់ចាករឿងដើម ឬបញ្ចេញបញ្ចូលថែមខុសពីសាច់រឿងពិត សមស្របតាមទំនៀមទំលាប់ប្រពៃណីល្អ និង ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា រួចស្នើប្រគល់សៀវភៅក្នុងមួយមុខ ចំនួន ០៦ ច្បាប់រៀងរាល់លេខចេញផ្សាយមក តំកល់ ទុកជាឯកសារនៅក្រសួងពត៌មាន ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តិល្មើសអំពីសេចក្តីដូចមានចែងក្នុងប្រការ ១ និងប្រការ២ ខាងលើ សាម៉ីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៤ : អគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ នាយកមណ្ឌលពត៌មាន នៃក្រសួងពត៌មាន និង លោកប្រធាន អង្គការជំនួយសូតូស៊ូជប៉ុន ត្រូវអនុវត្តនូវប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះមានប្រសិទ្ធភាពត្រឹមការបោះពុម្ពចែកផ្សាយសៀវភៅចំនួនដប់មុខ និង

ផ្ទាំងរូបភាពចំនួនពីរ ដូចមានចែងក្នុងប្រការ ១ ខាងលើនេះតែប៉ុណ្ណោះ និង ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ១៩៩៦

ប្រកាសលេខ : ១៩២/៩៦ ពម.មពប្រក

អនុញ្ញាតអោយកាសែតឈ្មោះ «ភ្នំពេញ »បោះពុម្ពចែកផ្សាយ

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ជំពូក៣ មាត្រាទី ៤១
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ ស្តីពីរបបសារពត៌មាន នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើតាមព្រះរាជក្រម លេខ នស.រកម ០៨៩៥-០៧ ចុះថ្ងៃទី ០១ ខែ កញ្ញា ១៩៩៥
- បានឃើញសំណើសុំបោះពុម្ពកាសែតឈ្មោះ " ភ្នំពេញ " ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៩៩៦

សំរេច

ប្រការ ១ : អនុញ្ញាតអោយកាសែតឈ្មោះ"**ភ្នំពេញ**" បោះពុម្ពផ្សាយដោយមានលោកប៊ុន សិទធា ជាចាងហ្វាង ការផ្សាយ ។ ទីស្នាក់ការបណ្តោះអាសន្នសម្ព័ន្ធអ្នកសារពត៌មានកម្ពុជា ។ ក្នុងករណីមានការផ្លាស់ ប្តូរចំណុចណាមួយក្នុងអត្តសញ្ញាណ នៃកាសែតរបស់ខ្លួនត្រូវជូនដំណឹងជាមុន ០៥ ថ្ងៃមកក្រសួង ពត៌មាន ដើម្បីរង់ចាំសេចក្តីសំរេចជាថ្មី ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពចែកផ្សាយត្រូវគោរពតាមគោលការណ៍ក្រមសីលធម៌អ្នកកាសែត និង ឈរលើស្មារតីទទួលខុសត្រូវខ្ពស់ក្នុងវិជ្ជាជីវៈរបស់ខ្លួន ។ ខ្លឹមសារអត្ថបទត្រូវអនុវត្តន៍អោយបាន សមស្របតាមទំនៀមទំលាប់ប្រពៃណីល្អ និង ច្បាប់

នៃព្រះរាជាណាចក្រកម្ពុជា រួចស្នើប្រគល់កាសែតចំនួន ០៦ ច្បាប់រៀងរាល់លេខចេញផ្សាយមកតំកល់ទុកជាឯកសារនៅក្រសួងពតិមាន ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តល្មើសអំពីសេចក្តីដូចមានចែងក្នុងប្រការ ១ និងប្រការ ២ ខាងលើ សាម៉ីខ្លួន ត្រូវ ទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៤ : អគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ នាយកមណ្ឌលពតិមាន និង លោកចាងហ្វាងកាសែត "ភ្នំពេញ" ត្រូវអនុវត្តន៍នូវប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះមានប្រសិទ្ធភាពរយៈពេល ២ឆ្នាំ និង ចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៦

ប្រកាសលេខ : ១៩៣/៩៦ ពម.មព.ប្រក

ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

រដ្ឋមន្ត្រីក្រសួងពតិមាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងពតិមាន
- តាមការចាំបាច់របស់ក្រសួង
- ពិនិត្យលើលក្ខណៈសម្បត្តិ និង សមត្ថភាពមន្ត្រីរាជការ

សម្រេច

ប្រការ ១ : តែងតាំងមន្ត្រីរាជការចំនួន ០២ រូប ជាថ្នាក់អនុប្រធាននាយកដ្ឋាន នាយកដ្ឋានគ្រប់គ្រងការបោះពុម្ពផ្សាយ និង សោតទស្សន៍ នៃអគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ ដូចមានរាយនាមខាង ក្រោមនេះ ÷

- លោក **ឡាយ គីមឃាង** ជាអនុប្រធាននាយកដ្ឋានទទួលលេខាធិការដ្ឋាន និង ការិយាល័យ គ្រប់គ្រងអាហ្វីស និង ផ្លាកសញ្ញា
- លោក **ជឿម ដារ៉ា** ជាអនុប្រធាននាយកដ្ឋានទទួលការិយាល័យគ្រប់គ្រង រោងពុម្ព និង វិស័យបោះពុម្ពផ្សាយ ។

ប្រការ ២ : លោកនាយកខុទ្ទកាល័យ លោកអគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ លោកអគ្គនាយក បណ្តាអគ្គនាយកដ្ឋាន លោកប្រធាននាយកដ្ឋានរដ្ឋបាលបុគ្គលិក លោកប្រធាននាយកដ្ឋានផែនការគណនេយ្យ និងហិរញ្ញវត្ថុ និងអស់លោកក្នុងប្រការ ១ ត្រូវអនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃចុះ ហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

អៀង មូលី

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ១៩៩៦

ប្រកាសលេខ : ១៩៤/៩៦ ពម.ចសឧប្រក

អនុញ្ញាតអោយលោក IVAN J BROOKFIELD សញ្ជាតិ

អូស្ត្រាលីបើកស្ថានីយ៍វិទ្យុផ្សាយសម្លេង FMIOI MHZ

រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជ រដ្ឋាភិបាល

- បានឃើញព្រះរាជក្រម នស.រកម ០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងពត៌មាន
- ពិនិត្យលើសំណើសុំច្បាប់អនុញ្ញាតតម្លើងបើកស្ថានីយ៍វិទ្យុ FM 101 Mhz អនុភាពកំលាំងផ្សាយ 10Kw និងប្រព័ន្ធទូរទស្សន៍ PAY TV 30 MDS-2197 Mhz ទៅ 2407 Mhz ដែលមានឈ្មោះ VISIONSTAR ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ : អនុញ្ញាតអោយលោក IVAN J.BROOKFIELD សញ្ជាតិអូស្ត្រាលី កាន់លិខិតឆ្លងដែនលេខ J 1209542 បើកស្ថានីយ៍វិទ្យុផ្សាយសំលេង FM 101 Mhz អនុភាពកំលាំងផ្សាយតិចជាង ឬ អតិបរមា 10Kw និងកំពស់អង់តែនត្រឹមតែ ៩០ ម៉ែត្រ និងប្រព័ន្ធទូរទស្សន៍ PAY TV 30 MDS-2197 Mhz ទៅ 2407 Mhz ដែលមានឈ្មោះ VISIONSTAR PTY.LTD.

ប្រការ ២ : រាល់ដំណើរការផ្សព្វផ្សាយរបស់ស្ថានីយ៍វិទ្យុផ្សាយសំលេង និង ប្រព័ន្ធទូរទស្សន៍ PAY.TV នេះ ត្រូវគោរពតាមកិច្ចសន្យា និងច្បាប់បញ្ញត្តិបទបញ្ជា ឬសេចក្តីណែនាំខាងផ្នែកសោតទស្សន៍ទាំងឡាយ នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : ក្នុងករណីមិនគោរពតាមកិច្ចសន្យា សាមីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៤ : អគ្គនាយកវិទ្យុ-ទូរទស្សន៍ជាតិកម្ពុជា ប្រធាននាយកដ្ឋានគ្រប់គ្រងការបោះពុម្ពផ្សាយសោតទស្សន៍ នៃអគ្គនាយកដ្ឋានរដ្ឋបាល-ហិរញ្ញវត្ថុ មន្ទីរពត៌មានរាជធានីភ្នំពេញ និង អាជ្ញាធរដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះ មានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

អៀង មូលី

* * *

៤_ទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់និង នេសាទ

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៩៩៦

ប្រកាស លេខ : ៣៥៩ ប្រក.កសក.ចត

ស្តីពីការបង្កើតការិយាល័យអាស៊ាន កសិកម្ម

* * *

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ១៩៩៤ ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ១៩៨៤ ស្តីពីតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់ក្រសួងកសិកម្ម ។
- បានឃើញលិខិតលេខ ២៩៦ សជអាផក ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ១៩៩៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- តាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

សំរេច

មាត្រា ១ : បង្កើតការិយាល័យអាស៊ានកសិកម្ម ចំណុះនាយកដ្ឋានផែនការ និង សហប្រតិបត្តិការ នៃក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

មាត្រា ២ : ការិយាល័យអាស៊ានកសិកម្ម មានភារកិច្ច :

- ជាសេនាធិការអោយនាយកដ្ឋាន និង ក្រសួងធ្វើការទាក់ទង និង សំរបសំរួលដោះស្រាយរាល់បញ្ហាកសិកម្មកម្ពុជា ជាមួយនឹងអគ្គនាយកដ្ឋានអាស៊ាននៅក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ។

- ប្រមូលផ្តុំ និង លើកគំរោងអភិវឌ្ឍន៍គ្រប់ផ្នែកក្នុងវិស័យកសិកម្មសំរាប់អាស៊ាន ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ និង សំរេច ។
- សហការ និង សំរបសំរួលជាមួយអង្គភាពពាក់ព័ន្ធ អនុវត្តកិច្ចការអាស៊ាននៅក្នុងក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ អោយដំណើរការបានល្អស្របតាមកិច្ចការអភិវឌ្ឍន៍របស់ សមាគមអាស៊ាន ។

មាត្រា ៣ : ក្របខ័ណ្ឌមន្ត្រីរាជការ របស់ការិយាល័យអាស៊ានកសិកម្ម អាស្រ័យដោយនាយកដ្ឋានផែនការ និង សហប្រតិបត្តិការកំណត់សំរេច ។

មាត្រា ៤ : ការិយាល័យអាស៊ានកសិកម្ម ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានជំនួយការ ។

មាត្រា ៥ : អគ្គនាយកក្រសួង ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានផែនការ និង សហប្រតិបត្តិការ ព្រមទាំងអង្គភាពពាក់ព័ន្ធត្រូវអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

តាវ សេងហួរ

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៩៩៦

ប្រកាស លេខ : ៣៦០ ប្រក.កសក.ចន

ស្តីពីការរំសាយអង្គភាព

* * *

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤–៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ១៩៩៤ ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៨៤ ស្តីពីតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់ក្រសួងកសិកម្ម
- បានឃើញប្រកាសលេខ ៤១១ ប្រក.កសក.ចត ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩២ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់នាយកដ្ឋានក្សេត្រសាស្ត្រ
- តាមសំណើរបស់នាយកដ្ឋានក្សេត្រសាស្ត្រ

សម្រេច

មាត្រា ១ : ត្រូវបានរំសាយស្ថានីយ៍ពិសោធន៍ស្រាវជ្រាវពូជថ្នាំជក់សំរោងធំ ចាប់ពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៩៦ ចេញពីរសម្ព័ន្ធចាត់តាំងរបស់នាយកដ្ឋានក្សេត្រសាស្ត្រ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

មាត្រា ២ : មន្ត្រី បុគ្គលិក កម្មករ របស់ស្ថានីយ៍នេះ ដែលស្ម័គ្រចិត្តសុំលាឈប់ និង និងសុំមកបំរើការងារនៅ នាយកដ្ឋានក្សេត្រសាស្ត្រ ត្រូវកំណត់តាមប្រកាសដោយឡែក ។

មាត្រា ៣ : សេចក្តីសំរេចណា ដែលពាក់ព័ន្ធនឹងស្ថានីយ៍ពិសោធន៍ស្រាវជ្រាវពូជថ្នាំជក់សំរោងធំ ហើយមានខ្លឹម សារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៤ : អគ្គនាយកក្រសួង ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការស្ថិតិ ប្រធាននាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ និង ប្រធាននាយកដ្ឋានក្សេត្រសាស្ត្រ ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀង ។ ខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

តាវ សេងហួរ

* * *

៥_ ឯកសារក្រសួងអប់រំ យុវជន និងកីឡា

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៩៦

ប្រកាសលេខ ៦២២ អយក.ប្រក

ស្តីពីការប្តូរឈ្មោះ សាលាបឋមសិក្សា «ហ៊ុន សែន_អ្នកលឿង»

* * *

រដ្ឋមន្ត្រីអប់រំ យុវជន និង កីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យព្រះបាទសម្តេច ព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១_១១_១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០_៧_១៩៩៤
- បានឃើញក្រឹត្យច្បាប់លេខ ៣០ ក្រច ចុះថ្ងៃទី ២០_១១_១៩៨៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ
- បានពិនិត្យលិខិតស្នើសុំរបស់ការិយាល័យអប់រំ យុវជននិងកីឡា ស្រុកពាមរក៍ លេខ ៤៦_៩៦ អយក.ពរ ចុះថ្ងៃទី ២៩_៣_១៩៩៦ ដោយមានចំណារឯកភាពរបស់អភិបាលខេត្តរង ទី ២ ចុះថ្ងៃទី ០៨_៥_១៩៩៦
- តាមយោបល់ឯកភាពរបស់នាយកដ្ឋាន ចំនេះទូទៅ និង មត្តេយ្យសិក្សា

សំរេច

ប្រការ ១ : អនុញ្ញាតអោយមន្ទីរអប់រំ យុវជន និងកីឡា ខេត្តព្រៃវែង ប្តូរឈ្មោះសាលាបឋមសិក្សា អ្នកលឿង នៅស្រុកពាមរក៍ ខេត្តព្រៃវែង មកជាសាលាបឋមសិក្សា «**ហ៊ុន សែន អ្នកលឿង**» វិញ ចាប់ពីឆ្នាំសិក្សា ១៩៩៥_១៩៩៦ នេះតទៅ ។

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៣ : ប្រធានមន្ទីរ ក្រសួងអប់រំ យុវជន និងកីឡា ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ ហិរញ្ញកិច្ច ប្រធាននាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា ប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្តព្រៃវែង ប្រធានការិយាល័យអប់រំ យុវជន និងកីឡា ស្រុកពាមរក៍ នាយកដ្ឋានសាលាបឋមសិក្សា «ហ៊ុន សែន_អ្នកលឿង» មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

តូល ឡោះ

* * *

៦_ ទីស្តីការក្រសួងធម្មការ និងសាសនា

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៦

ប្រកាសលេខ ១២០ កធស ស្តីពីការតែងតាំង

គណៈកម្មការអភិវឌ្ឍន៍ពុទ្ធិកសិក្សា

* * *

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១_១១_៩៣
- បានឃើញព្រះរាជក្រមលេខ នស.រកម ១០៩៦-១៩ ចុះថ្ងៃទី ២៤ ខែ មករា ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា
- យោងតាមការចាំបាច់របស់ក្រសួងធម្មការ និង សាសនា

សំរេច

ប្រការ ១ : បង្កើតគណៈកម្មការអភិវឌ្ឍន៍ពុទ្ធិកសិក្សាមួយ ដែលមានសមាសភាពដូចតទៅ :

១- ឯកឧត្តម **ហឿន វណ្ណារិទ្ធ** រដ្ឋលេខាធិការ ប្រធាន

២- ឯកឧត្តម **ដោក ណារិន** អនុរដ្ឋលេខាធិការទទួលបន្ទុកអគ្គាធិការ

	ដ្ឋានពុទ្ធិសិក្សា	អនុប្រធាន
៣– ឯកឧត្តម **ឈាន ឈឿម**	អនុរដ្ឋលេខាធិការទទួលបន្ទុក	
	ពុទ្ធសាសនបណ្ឌិត្យ	សមាជិក
៤– សម្តេចព្រះសង្ឃរាជគណៈមហានិកាយ ឬ តំណាង		សមាជិក
៥– សម្តេចព្រះសង្ឃរាជធម្មយុត្តិកនិកាយ ឬ តំណាង		សមាជិក
៦– សម្តេចព្រះមង្គលទេពាចារ្យ **អ៊ុំ ស៊ុំ** អគ្គាធិការពុទ្ធិកសិក្សា		សមាជិក
៧– ព្រះពុទ្ធឃោសា ឈាងលាងហោ	នាយកពុទ្ធិកវិទ្យាល័យ	សមាជិក
៨–លោក **យី ឆន់**	ទីប្រឹក្សាក្រសួង	សមាជិក
៩–តំណាងរដ្ឋមន្ត្រី	ក្រសួងអប់រំ យុវជននិងកីឡា	សមាជិក
១០–លោក **ហង់ ច័ន្ទ**	អគ្គាធិការរងទី១	សមាជិក
១១–លោក **ទេព ផុន**	អគ្គាធិការរង ទទួលបន្ទុកពុទ្ធិកសិក្សា	សមាជិក
១២–លោក **ម៉ែន ប្រាង**	មន្ត្រីពុទ្ធសាសនា បណ្ឌិត្យ	សមាជិក
១៣–លោក **គីន ណាន**	សាស្ត្រាចារ្យភាសាសំស្ក្រឹត	សមាជិក
១៤–លោក **អ៊ុំ វណ្ណៈ**	អនុប្រធានការិយាល័យ	
	ពុទ្ធិកមធ្យមសិក្សាលេខាកត់ត្រា	សមាជិក
១៥–លោក **រស់ សារ៉េន**	នាយករងពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត	សមាជិក

ប្រការ ២ : គណៈកម្មការនេះ មានភារកិច្ចដឹកនាំការងារពុទ្ធិកសិក្សាទូទាំងប្រទេស ដូចជាការរៀបចំកម្មវិធីសិក្សា ផែនការអប់រំទូទៅ ច្បាប់ផ្សេង ៗ ដែលទាក់ទង និងពុទ្ធិកសិក្សាឧបករណ៍សំភារៈសំរាប់ស្រាវជ្រាវ ។

ប្រការ ៣ : គណៈកម្មការខាងលើចូលរួមប្រជុំតាមការអញ្ជើញរបស់ឯកឧត្តម ប្រធាន ។

ប្រការ ៤ : សមាសភាពគណៈកម្មការអភិវឌ្ឍន៍ពុទ្ធិកសិក្សា មានភារកិច្ចរៀង ៗ ខ្លួនអនុវត្តប្រកាសនេះ អោយមានប្រសិទ្ធភាពចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

ឃឿន វណ្ណារ័ត្ន

បោះពុម្ពនៅរោងពុម្ពទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី ១ ចំនួន ២៨០០ ច្បាប់

តម្លៃ ៩០០ រៀល